# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

# របាយការណ៍
# បូកសរុបលទ្ធផលការងារសុខភាពសត្វ និងផលិតកម្មសត្វ
# ប្រចាំឆ្នាំ២០១៨ និងលើកទិសដៅការងារឆ្នាំ២០១៩

**ថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០១៩**

**រៀបចំដោយ៖ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

ភូមិទ្រា ផ្លូវលេខ៣៧១ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ
Trea Village, Str371, Sangkat Steung Mean Chey, Khan Mean Chey, Phnom Penh Cambodia
ទូរស័ព្ទលេខ (៨៥៥) ២៣៨៨៣៧៤៦/៨៨៤ ១៤៨ ទូរសារៈ (៨៥៥) ២៣៨៨៣៧៤៦/៨៨៤ ១៤៨
Tel: (855) 23 883 746/884 148 Fax: (855) 23 883 746/884 148

# មាតិកា

ទំព័រ


I.**សេចក្តីផ្តើម**..........01
II.**គោលនយោបាយ និងយុទ្ធសាស្ត្រអនុវត្តរបស់រាជរដ្ឋាភិបាល**..........0២
១.យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល២០១៤-២០១៨..........0២
២.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨..........0៣
៣.ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥..........0៣
៤.គោលនយោបាយ និងយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤-២០១៨......0៣
៥.ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥..........0៣
៦.ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៧-២០១៩........0៤
III.**លទ្ធផលជារួម**..........0៤
IV.**លទ្ធផលជំរុញផលិតកម្មសត្វ និងសុខភាពសត្វ**..........0៦
**១.ការជំរុញការចិញ្ចឹមសត្វ និងបង្កើនផលិតភាពសត្វ**..........0៦
១.១.ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ..........0៦
១.២.ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម..........0៧
១.៣.ស្ថិតិសត្វសរុបទូទាំងប្រទេស..........0៨
១.៤.ការប្រៀបធៀបបែបផែនផលិតកម្មតាមប្រភេទសត្វ..........0៩
១.៥.តម្រូវការសត្វ និងសាច់..........១0
១.៦.ការនាំចេញសត្វ និងផលិតផលសត្វ..........១១
១.៧.កម្មវិធីកែលម្អពូជ..........១២
១.៨.អំពីចំណីសត្វ..........១២
១.៩.ការគ្រប់គ្រងកាកសំណល់សត្វ..........១៣
**២.ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈ**..........១៣
២.១.ការលើកកម្ពស់សុខភាពសត្វ..........១៤
២.២.ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល..........១៤
**៣.ការផ្សព្វផ្សាយបច្ចេកទេសនិងបសុព្យាបាល និងនីតិកម្ម**..........១៥
៣.១.ការផ្សព្វផ្សាយបច្ចេកទេស..........១៥
៣.២.ការងារនីតិកម្ម..........១៥
**៤.ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ**..........១៧
៤.១.ការងារស្រាវជ្រាវសុខភាពសត្វ..........១៧
៤.២.ការងារស្រាវជ្រាវផលិតកម្មសត្វ..........១៨

**៥.ការងារពង្រឹងសមត្ថភាពអង្គភាព សេវាគាំទ្រ និងការអភិវឌ្ឍន៍ធនធានមនុស្ស**.....១៨
៥.១.ការពង្រឹងការគ្រប់គ្រងអង្គភាព.....១៨
៥.២.ការអភិវឌ្ឍន៍ធនធានមនុស្ស.....១៨
៥.៣.ការងាររៀបចំផែនការ.....១៩
៥.៤.ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ.....១៩
៥.៥.ការងារសហប្រតិបត្តិការ.....២០
ក.កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍.....២០
ខ.កិច្ចសហការអន្តរជាតិ និងអង្គការសង្គមស៊ីវិល.....២០
គ.កម្មវិធី និងគម្រោងសំខាន់ៗកំពុងអនុវត្ត.....២០
V.**ភាពលំបាក និងបញ្ហាប្រឈម**.....២០
VI.**ទិសដៅអនុវត្តឆ្នាំ២០១៩-២០២០**.....២១
ក.សូចនាករទិសដៅ.....២១
ខ.វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់.....២១
VII.**សេចក្តីសន្និដ្ឋាន**.....២២
VIII.**បញ្ជីឧបសម្ព័ន្ធ**.....២៤

# របាយការណ៍បូកសរុបលទ្ធផល
# ការងារសុខភាពសត្វ និងផលិតកម្មសត្វ ប្រចាំឆ្នាំ២០១៨
# និងទិសដៅការងារឆ្នាំ២០១៩

## I. សេចក្តីផ្តើម

ផលិតកម្មសត្វមានសក្តានុពលក្នុងការរួមចំណែកបង្កើតការងារ សន្តិសុខស្បៀង អាហាររូបត្ថម្ភ កំណើនសេដ្ឋកិច្ច និងចូលរួមចំណែកកាត់បន្ថយភាពក្រីក្រ។

ដោយអនុវិស័យនេះ ជាផ្នែកសំខាន់សម្រាប់ទ្រទ្រង់វិស័យកសិកម្ម និងសេដ្ឋកិច្ច រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ បានដាក់បញ្ចូលវិស័យកសិកម្មក្នុងចតុកោណទី៤ មុំទី១ ចំណុចអាទិភាពទី៧ ចែងពីការជំរុញការចិញ្ចឹមសត្វ និងវារីវប្បកម្ម ដើម្បីលើកកម្ពស់ការចិញ្ចឹមសត្វឱ្យកាន់តែទូលំទូលាយថែមទៀត តាមរយៈការបង្កើតក្របខ័ណ្ឌគោលនយោបាយផ្អែកលើខ្សែច្រវ៉ាក់តម្លៃ និងដោះស្រាយជាកញ្ចប់នូវបញ្ហាជាឧបសគ្គដល់ការអភិវឌ្ឍន៍អនុវិស័យនេះ ជាមួយគ្នានឹងការគិតគូដល់បញ្ហាសុវត្ថិភាពចំណីអាហារ និងកិច្ចដំណើរការទីផ្សារ ពិសេសអនាម័យ និងភូតគាមអនាម័យ។

ដើម្បីគាំទ្រដល់ទិសដៅអាទិភាពរបស់រាជរដ្ឋាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាដែលមានជាអាទិ៍៖ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ ផែនការយុទ្ធសាស្ត្រថវិកា ផែនការសកម្មភាពអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥ និងផែនការសកម្មភាពពាក់ព័ន្ធនានា។ ជារៀងរាល់ឆ្នាំអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំកិច្ចប្រជុំត្រួតពិនិត្យវាយតម្លៃវឌ្ឍនភាព និងសមិទ្ធផលសម្រេចបាននៃការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលបានដាក់ចេញ និងរកដំណោះស្រាយចំពោះបញ្ហាប្រឈម និងលើកទិសដៅសម្រាប់អនុវត្តឆ្នាំបន្ទាប់។

ដោយឡែកឆ្នាំនេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មិនត្រឹមតែពិនិត្យវាយតម្លៃលទ្ធផលប្រចាំឆ្នាំ ប៉ុន្តែក៏បានពិនិត្យនិន្នាការ និងលទ្ធផលការងារ៥ឆ្នាំចុងក្រោយ។ ជាក់ស្តែងសន្និបាតបូកសរុបការងារសុខភាពសត្វ និងផលិតកម្មសត្វឆ្នាំនេះ មានចរិកលក្ខណៈជាការបូកសមិទ្ធផលសំខាន់ៗនៃអនុវិស័យសុខភាពសត្វ និងផលិត-កម្មសត្វ ដើម្បីជាមូលដ្ឋានគ្រឹះសម្រាប់ដាក់ចេញនូវទិសដៅការងារអាទិភាពនៃអនុវិស័យនេះសម្រាប់ឆ្នាំបន្ទាប់ សំដៅឆ្លើយតបនឹងដំណើរការអភិវឌ្ឍន៍រីកចម្រើននៃសេដ្ឋកិច្ចសង្គម និងវប្បធម៌ទាំងនៅថ្នាក់ជាតិ តំបន់ និងពិភពលោក។

តាមរយៈសន្និបាតនេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានដាក់ចេញនូវយុទ្ធសាស្ត្រផែនការសកម្មភាព និងទិសដៅការងារអាទិភាពសម្រាប់ឱ្យគ្រប់នាយកដ្ឋាន វិទ្យាស្ថាន ការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី-ខេត្តទាំង២៥ បន្តអនុវត្តសំដៅលើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីសុខភាពសត្វ និងផលិតកម្មសត្វ ប្រមូលផ្តុំកម្លាំងមហាជនពីគ្រប់មជ្ឈដ្ឋានឱ្យចូលរួមកាន់តែសកម្មថែមទៀត ក្នុងកិច្ចអភិវឌ្ឍន៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ការពារសុខភាពមនុស្ស សុខភាពសត្វ សុខុមាលភាពសត្វ និងបរិស្ថានតាមរយៈកម្មវិធីបង្ការ និងលុបបំបាត់ជំងឺឆ្លងសត្វ និងជំងឺស៊ូណូស ធានានិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់តម្រូវការក្នុងស្រុក និងការនាំចេញ។

សន្និបាតនេះ បានលើកយកនូវប្រធានបទសំខាន់មួយចំនួនសម្រាប់ធ្វើការពិភាក្សារួមមាន៖ ១). ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ និងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥ ២). លទ្ធផលនៃការអង្កេតតាមដាន និងស្រាវជ្រាវជំងឺឆ្លងសត្វ សុវត្ថិភាពចំណីអាហារ និងវឌ្ឍនៈភាព

នៃការកែលម្អពូជគោ ៣). ជំរុញការគ្រប់គ្រង និងកែលម្អអនាម័យសត្តឃាតដ្ឋាន ការពិឃាតសត្វ និងពង្រឹងការដឹកជញ្ជូនសាច់ ៤). វឌ្ឍនភាពផលិតកម្មសត្វឆ្នាំ២០១៨ និងទិសដៅអនុវត្តឆ្នាំ២០១៩ និង៥). វឌ្ឍនភាពនៃការងារផ្សព្វផ្សាយបច្ចេកទេស និងនីតិកម្ម។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំយ៉ាងទៀងទាត់ជាមួយវិស័យឯកជន កសិករ ដៃគូអភិវឌ្ឍន៍ ក្រសួងពាក់ព័ន្ធ និងប្រជុំអនុក្រុមការងារបសុពេទ្យនៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹកបានកំណត់យក៖ ១). ពង្រឹងការកសាង និងអនុវត្តច្បាប់សុខភាពសត្វ និងផលិតកម្មសត្វ ២). បង្កើនការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម ៣). ការពារសុខភាពសត្វ និងសុខភាពសាធារណៈ ៤). បង្កើត និងពង្រឹងសហគមន៍ចិញ្ចឹមសត្វ និង៥). បង្កើនការស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមសត្វ។

មុខព្រួញអាទិភាពទាំង៥នេះ ជាសសរស្តម្ភ និងជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំពិនិត្យឡើងវិញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីធានាឱ្យបាននូវការអភិវឌ្ឍន៍អនុវិស័យនេះប្រកបដោយចីរភាពស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រដ្ឋាភិបាល។

ឆ្នាំ២០១៨នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សម្រេចបាននូវសមិទ្ធផលសំខាន់ៗមួយចំនួនឆ្លើយតបនឹងទិសដៅអាទិភាពនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ មានជាអាទិ៍ ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥ និងពង្រឹងរចនាសម្ព័ន្ធអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។ ជំរុញ និងលើកទឹកចិត្តលើការវិនិយោគរោងចក្រផលិតចំណីសត្វ និងកែលម្អការគ្រប់គ្រងសត្តឃាតដ្ឋាន អនាម័យ សេវាកម្ម ព្រមទាំងពង្រឹងកម្មវិធីបង្កាទប់ស្កាត់ និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វក្នុងក្របខ័ណ្ឌជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងចូលរួមយ៉ាងសកម្មក្នុងការពង្រឹងសេវាកម្មសុខភាពសត្វនៃអង្គការសុខភាពសត្វពិភពលោក។

លទ្ធផលដែលសម្រេចបាននេះ អាស្រ័យដោយមានគោលនយោបាយត្រឹមត្រូវរបស់រាជរដ្ឋាភិបាល មានការគាំទ្រពីធនធានថវិកាជាតិ ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ វិស័យឯកជន និងការខិតខំរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដោយមានកិច្ចសហការល្អប្រសើរជាមួយអាជ្ញាធរមូលដ្ឋាន សហគមន៍ចិញ្ចឹមសត្វ សមាគមអ្នកចិញ្ចឹមសត្វ និងអ្នកពាក់ពន្ធ័។

## II. គោលនយោបាយ និងយុទ្ធសាស្ត្រអនុវត្តរបស់រាជរដ្ឋាភិបាល

ដើម្បីធ្វើឱ្យសម្រេចនូវគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពរាជរដ្ឋាភិបាលបានដាក់ចេញនូវ៖

**១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល** លើកស្ទួយវិស័យកសិកម្មដែលក្នុងនោះមានបានកំណត់កម្មវិធីអាទិភាពលើកស្ទួយផលិតកម្មសត្វ និងសុខភាពសត្វ និងដាក់ចេញនូវទិសដៅចំនួន៤គឺ៖

ក. ជំរុញការរៀបចំ និងដាក់ឱ្យអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រលើកកម្ពស់ការចិញ្ចឹមសត្វ។

ខ. ជំរុញការលើកកម្ពស់ការស្រាវជ្រាវ និងការអភិវឌ្ឍន៍លើការបង្កាត់ពូជ ការគ្រប់គ្រងសុខភាពសត្វ និងការផលិតចំណីសត្វ និងប្រព័ន្ធកសិដ្ឋាន។

គ.ជំរុញអនុម័តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីជាមូលដ្ឋានសម្រាប់រៀបចំអង្គភាព និងគ្រប់គ្រងក្នុងគោលដៅពង្រឹងការអនុវត្តស្តង់ដារអនាម័យលើផលិតផលពីសត្វ ការពង្រឹង និងការអនុវត្តវិធានការអនាម័យភូតគាមអនាម័យ ដើម្បីបង្ការ ទប់ស្កាត់ លុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ និងការពារសុខភាពសាធារណៈ។

ឃ.ជំរុញលើកទឹកចិត្តការវិនិយោគលើការផលិតចំណីសត្វក្នុងទ្រង់ទ្រាយមធ្យម និងធំ ដើម្បីគាំទ្រដល់ចលនាចិញ្ចឹមសត្វរួមជាមួយការលើកកម្ពស់ប្រព័ន្ធផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន ការលើកទឹកចិត្តវិនិយោគឯកជន

ក្នុងការកែច្នៃផលិតផលសត្វ ការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងមានការសម្រួលពាណិជ្ជកម្មសត្វ និងផលិតផលសត្វ។

**២. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ (ASDP 2014-2018)** បានកំណត់ទិសដៅគោលនយោបាយរបស់ក្រសួងសម្រាប់អនុវត្តរយៈពេល៥ឆ្នាំគឺ "ជំរុញកំណើនវិស័យកសិកម្មប្រចាំឆ្នាំឱ្យបានក្នុងរង្វង់៥% តាមរយៈការលើកកម្ពស់ផលិតភាព ពិពិធកម្មភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្មដោយយកចិត្តទុកដាក់ខ្ពស់លើការការពារ និងគ្រប់គ្រងធនធានព្រៃឈើ និងជលផលប្រកបដោយនិរន្តរភាព"។

**៣.ផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥** ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក្នុងការរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាប័ន្នតាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រីកការប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

ចំណុចគន្លឹះពាក់ព័ន្ធនឹងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ជាការតម្រង់ទិសការអភិវឌ្ឍន៍តំបន់កែច្នៃផលិតផលសត្វ ជាលក្ខណៈប្រមូលផ្តុំ ដែលមានសក្តានុពលសម្រាប់ប្រើប្រាស់ក្នុងស្រុក និងនាំចេញ។ យន្តការគន្លឹះដែលត្រូវយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍន៍កសិឧស្សាហកម្មនោះ គឺការសម្របសម្រួល និងលើកទឹកចិត្តដល់វិស័យឯកជនក្នុងការវិនិយោគលើបច្ចេកទេសកែច្នៃផលិតកម្មសត្វស្របតាមស្តង់ដារផលិតផលអាស៊ាន និងតម្រូវការទីផ្សារអន្តរជាតិ។ ការផ្សារភ្ជាប់រវាងក្រុមអ្នកផលិតជាមួយអ្នកប្រមូលទិញតាមយន្តការ **"ផលិតកម្មកសិកម្មតាមកិច្ចសន្យា"** ដើម្បីធានាការផ្គត់ផ្គង់កសិផលប្រកបដោយនិរន្តរភាព គឺជាចំណុចយុទ្ធសាស្ត្រដ៏សំខាន់។

បន្ថែមលើសពីនេះទៀត ការលើកកម្ពស់វិធានអនាម័យ និងភូតគាមអនាម័យត្រូវបានយកចិត្តទុកដាក់លើការកសាងក្របខ័ណ្ឌគតិយុត្ត និងបច្ចេកវិទ្យា ព្រមទាំងពង្រីក និងពង្រឹងសមត្ថកិច្ចត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យនៅតាមច្រកព្រំដែន ដើម្បីសម្រួលពាណិជ្ជកម្ម ការធ្វើសមាហរណកម្មសេដ្ឋកិច្ច និងទទួលបានទីផ្សារផលិតផលកសិកម្មក្នុងតំបន់ និងអន្តរជាតិ។

**៤. គោលនយោបាយ និងយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤-២០១៨** ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានកំណត់គោលបំណងបង្កើនធនធាន និងការបន្សាំ តាមរយៈការអភិវឌ្ឍន៍បច្ចេកវិទ្យាលើការកែលម្អពូជសត្វ ចំណីសត្វ សុខភាពសត្វ ការគ្រប់គ្រងកាកសំណល់សត្វ និងការកាត់បន្ថយការបំភាយឧស្ម័ន។

**៥.ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ២០១៦-២០២៥** ដែលដាក់ឱ្យអនុវត្តកាលពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ កន្លងមក បានកំណត់នូវចក្ខុវិស័យនៃក្របខ័ណ្ឌផែនការនេះគឺ "ការអភិវឌ្ឍន៍វិស័យបសុសត្វប្រកបដោយនិរន្តរភាព ធានាបាននូវសន្តិសុខស្បៀង សុវត្ថិភាពចំណីអាហារ និងការធ្វើពាណិជ្ជកម្មប្រកបដោយប្រាក់ចំណេញ និងរួមចំណែកដល់កំណើនសេដ្ឋកិច្ចជាតិ"។ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រនេះ ជំរុញឱ្យមានការអនុវត្តកម្មវិធីលើកស្ទួយសុខភាពសត្វ និងផលិតកម្មសត្វ តាមរយៈការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ការស្រាវជ្រាវ និងផ្សព្វផ្សាយ ការរៀបចំគោលនយោបាយ និងពង្រឹងការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ការអភិវឌ្ឍន៍ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ដែលមានទិសដៅអាទិភាពចំនួន៨គឺ:

១. ពង្រឹងផលិតកម្មសត្វ រួមទាំងលើកកម្ពស់ការគ្រប់គ្រង និងការបង្កាត់ពូជសត្វ
២. ពង្រឹងសុខភាពសត្វ សុខភាពសាធារណៈបសុព្យាបាល និងសុខុមាលភាពសត្វ
៣. លើកកម្ពស់ការផ្សព្វផ្សាយច្បាប់ ពង្រឹងការអនុវត្តច្បាប់ និងគោលនយោបាយនានា
៤. ជំរុញការងារស្រាវជ្រាវ និងអភិវឌ្ឍន៍ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
៥. បង្កើនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ
៦. លើកកម្ពស់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជននៅក្នុងវិស័យអភិវឌ្ឍន៍បសុសត្វ

៧. ពង្រឹងសេវាផ្សព្វផ្សាយសុខភាពសត្វ និងផលិតកម្មសត្វ និងការអភិវឌ្ឍន៍ទីផ្សារ

៨. ពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងបច្ចេកទេសកម្រិតជាតិ និងអន្តរជាតិលើអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

**៦.ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ២០១៧-២០១៩** បានត្រូវរៀបចំឡើងដោយឆ្លុះបញ្ចាំង និងឆ្លើយតបនឹងទិសដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការពាក់ព័ន្ធនានា បានត្រូវរៀបចំ និងកែលម្អ សំដៅគាំទ្រដល់គោលបំណង គោលនយោបាយរួមក្នុងការជំរុញកំណើនវិស័យកសិកម្មប្រចាំឆ្នាំឱ្យបានក្នុងរង្វង់៥% ដែលក្នុងនោះការលើកកម្ពស់ការចិញ្ចឹមសត្វ និងវារីវប្បកម្ម គឺជាកម្មវិធីអាទិភាពមួយក្នុងចំណោមកម្មវិធីអាទិភាពទាំង៥ ក្នុងការជំរុញកំណើនក្នុងវិស័យកសិកម្ម។

កម្មវិធីលើកកម្ពស់ការចិញ្ចឹមសត្វបានកំណត់នូវសូចនាករច្បាស់លាស់គឺ ជំរុញផលិតកម្មសត្វក្នុងកំណើន៣% ក្នុងមួយឆ្នាំ តាមរយៈការពង្រឹងសមត្ថភាព ពិសោធន៍ ស្រាវជ្រាវ និងផ្សព្វផ្សាយបច្ចេកទេសប្រកបដោយប្រសិទ្ធភាព កម្មវិធីបង្ការ ទប់ស្កាត់ជំងឺឆ្លងសត្វ និងជំងឺស៊ូណូសដើម្បីធានាដល់ការផ្គត់ផ្គង់សត្វ និងផលិតផលសត្វប្រកបដោយអនាម័យ និងសុវត្ថិភាពឈានទៅបង្កើនសក្តានុពលនៃការនាំចេញ។

## III. លទ្ធផលជារួម

ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វត្រូវបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាព ដែលសម្រេចបាននូវទិសដៅចំបងៗជាច្រើន ដើម្បីឆ្លើយតបទៅនឹងទិសដៅអាទិភាពនៃគោលនយោបាយ ក្នុងនោះរួមមាន៖

- កសាងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ឯកសារគតិយុត្ត គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ និងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វ១០ឆ្នាំ ២០១៦-២០២៥
- ពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍន៍ធនធានមនុស្ស ដោយបានដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នៅខែតុលា ឆ្នាំ២០១៦ និងរៀបចំបាននូវរចនាសម្ព័ន្ធស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទស្របតាមខ្លឹមសារអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧ និងការបង្កើនសមត្ថភាពដឹកនាំ គ្រប់គ្រង រៀបចំ និងអនុវត្តផែនការគម្រោងកម្មវិធី បង្កើនសមត្ថភាពបច្ចេកទេស រួមទាំងការអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ និងការបំពាក់ឧបករណ៍សម្ភារមន្ទីរពិសោធន៍សម្រាប់អនុវត្តតួនាទី ភារកិច្ចស្នូលរបស់អង្គភាព
- ការកសាងផែនការ និងយុទ្ធសាស្ត្រនានាសម្រាប់អនុវត្តច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រសំខាន់ៗដែលរួមមានផែនការជាតិលុបបំបាត់ជំងឺអុតក្តាម ដែលស្ថិតក្នុងក្របខ័ណ្ឌនៃយុទ្ធនាការតំបន់ក្នុងការប្រយុទ្ធប្រឆាំង និងលុបបំបាត់ជំងឺអុតក្តាមនៃអង្គការសុខភាពសត្វពិភពលោក ផែនការសកម្មភាពទប់ស្កាត់ជំងឺសំខាន់ៗមានជំងឺផ្តាសាយបក្សី ជំងឺអុតក្តាម សារទឹកគោ-ក្របី ជំងឺជ្រូកត្រចៀកខៀវ ផែនការសកម្មភាពកាត់បន្ថយ និងបន្សាំសម្រាប់អនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រឆ្លើយតបការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤-២០១៨ ផែនការសកម្មភាពអនុវត្តសម្រាប់អនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៨-២០២០ និងការបង្កើតទម្រង់របាយការណ៍ឯកភាពទូទាំងប្រទេសពាក់ព័ន្ធនឹងព័ត៌មានសុខភាពសត្វ និងផលិតកម្មសត្វ ដែលមានលក្ខណៈសាមញ្ញគ្រប់ជ្រុងជ្រោយ ហើយគ្របដណ្តប់លើប្រភេទទិន្នន័យសំខាន់ៗជាមូលដ្ឋានគ្រឹះសម្រាប់វិភាគ វាយតម្លៃ និងរៀបចំផែនការនានា

- ការកែទម្រង់ស៊ីជម្រៅក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វសម្រាប់គាំទ្រដល់ចលនាចិញ្ចឹមសត្វ រួមជាមួយនឹងការលើកកម្ពស់ផ្តល់សេវាបច្ចេកទេស ពូជ ឥណទាន និងការសម្របសម្រួលទីផ្សារជូនផ្នែកឯកជន និងកសិករចិញ្ចឹមសត្វ ការកែច្នៃសាច់ ផលិតផលសត្វ និងការបង្កើតសត្តឃាតដ្ឋានទំនើប ព្រមទាំងការសម្រួលដល់ការធ្វើពាណិជ្ជកម្មសត្វ និងផលិតផលសត្វ ដោយទទួលបានគោលការណ៍ឯកភាពពីរាជរដ្ឋាភិបាលក្នុងការកែទម្រង់ការគ្រប់គ្រងសត្តឃាតដ្ឋាន។ ការបង្កើតស្ថានីយ៍ចត្តាឡីស័កសត្វ កន្លែងត្រួតពិនិត្យសត្វ និងផលិតផលសត្វដើមទី និងចុងទី ការបង្កើតគណៈកម្មាការគ្រប់គ្រងហានិភ័យសុខភាពសត្វ និងផលិតកម្មសត្វ បំពេញតួនាទីត្រួតពិនិត្យប្រភពដើមសត្វ និងផលិតផលសត្វ ដើម្បីទប់ស្កាត់ជំងឺឆ្លងរាលដាលសត្វ ការពារសុខភាពសត្វ និងសុខភាពសាធារណៈ លើកការនាំចូល នាំចេញ នាំឆ្លងកាត់សត្វ និងផលិតផលសត្វ។ ជាពិសេសគៀរគរវិស័យឯកជនឱ្យមកវិនិយោគក្នុងអនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងនាំចេញ។

ដោយសារមានខឿនរឹងមាំនៃគោលនយោបាយ ច្បាប់ និងមានផែនការយុទ្ធសាស្ត្រមានលក្ខណៈគ្រប់ជ្រុងជ្រោយ រួមជាមួយការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សប្រកបដោយគុណភាព ការគ្រប់គ្រងអនុវិស័យនេះមិនត្រឹមតែជំនះបានគ្រប់នូវឧបសគ្គនានា តែសម្រេចបានសមិទ្ធផលសំខាន់ជាច្រើន។ ការចិញ្ចឹមជ្រូកលក្ខណៈគ្រួសារមានការថយចុះ ដោយសារការអូសបន្លាយពីការផលិតជ្រូកលើសតម្រូវការពីប្រទេសជិតខាងចាប់ពីឆ្នាំ២០១៧ ដល់ដើមឆ្នាំ២០១៨ ជាពិសេសទីផ្សារប្រទេសចិនមិនបញ្ជាទិញជ្រូកពីប្រទេសវៀតណាមនាំឱ្យមានលំហូរជ្រូករស់មកកម្ពុជាវិញ ធ្វើឱ្យតម្លៃជ្រូកចុះថោកប៉ះពាល់យ៉ាងខ្លាំងដល់ផលិតកម្មជ្រូកក្នុងស្រុក មិនអាចប្រកួតប្រជែងទាំងគុណភាព ថ្លៃដើមផលិត និងសេវាកម្មនានា។ ព្រឹត្តិការណ៍បានប្រែក្លាយទៅជាកំលាំងជំរុញឱ្យអ្នកចិញ្ចឹមជ្រូកមានបទពិសោធន៍ពីការចិញ្ចឹម ដឹងពីតម្រូវការក្នុងស្រុក ការជ្រើសរើសពូជ និងរដូវកាល។ បន្ទាប់ពីសភាពការណ៍នេះស្ងប់ស្ងាត់ក្នុងឆ្នាំ ២០១៨ ការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មមានការកើនឡើង។

ការអនុវត្តគោលនយោបាយ ច្បាប់ ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានា នាពេលប៉ុន្មានឆ្នាំនេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សម្រេចបាននូវលទ្ធផលសំខាន់ៗជាច្រើន ដែលលទ្ធផលទាំងនោះស្តែងចេញតាមរយៈការកើនឡើងនូវការវិនិយោគលើផលិតផលចំណីសត្វ។ បច្ចុប្បន្ននេះមានក្រុមហ៊ុន និងសហគ្រាសវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វចំនួន១៦ក្រុមហ៊ុន មានរោងចក្រ១៨កន្លែង ប៉ុន្តែមានក្រុមហ៊ុនចំនួន ១៥ក្រុមហ៊ុន រោងចក្រចំនួន១៧កន្លែងកំពុងដំណើរការ។ បន្ថែមពីនេះ សត្តឃាតដ្ឋាននៅក្នុងស្រុកសរុបមានចំនួន ១៧៥ ក្នុងនោះមានសត្តឃាតដ្ឋានពិឃាតគោទំនើបខ្នាតអន្តរជាតិចំនួន១ និងសត្តឃាតដ្ឋានបក្សីទំនើបចំនួន១។ ការវិនិយោគបង្កើតកសិដ្ឋានចិញ្ចឹមជ្រូក និងសត្វស្លាប មួយចំនួនទៀតកំពុងដំណើរការ និងគម្រោងវិនិយោគចិញ្ចឹមគោយកទឹកដោះកំពុងសិក្សា។ ឆ្នាំ២០១៨នេះ ស្ថិតិសត្វចិញ្ចឹមសរុបបានកើនដល់៤៤,៣៧លានក្បាលបើធៀបនឹងឆ្នាំ២០១៧ គឺមានកំណើន៣,៦% ជាពិសេសកំណើនផលិតកម្មសត្វជាលក្ខណៈពាណិជ្ជកម្ម។ ជាមួយនឹងកំណើននេះ កម្ពុជាអាចផ្គត់ផ្គង់សាច់បាន៨១%នៃតម្រូវការសរុប២៣១.២៨៣តោន ដោយមិនរាប់បញ្ចូលតម្រូវការសម្រាប់ភ្ញៀវ-ទេសចរចំនួន៦លាននាក់នៅឆ្នាំ២០១៨ ឡើយ។

ក្នុងឆ្នាំ២០១៨ នេះ ដោយមានការត្រៀមលក្ខណៈបានល្អ និងយកចិត្តទុកដាក់ខ្ពស់លើការងារអង្កេតតាមដានស្រាវជ្រាវប្រភពចម្លងជំងឺ និងមានប្រព័ន្ធរាយការណ៍ស្ថានភាពសុខភាពសត្វជាប្រចាំ ករណីផ្ទុះជំងឺឆ្លងត្រូវបានរកឃើញ និងរាយការណ៍បានឆាប់រហ័ស និងបានចាត់វិធានការឆ្លើយតបទាន់ពេលវេលា។ លើសពីនេះទៀតការផ្ទុះជំងឺឆ្លងសត្វជាពិសេសជំងឺផ្តាសាយបក្សីចំនួន៧ករណី និងមិនមានករណីផ្ទុះជំងឺបេស្តជ្រូកអាហ្វ្រិកនៅកម្ពុជាឡើយ។ ក្នុងឆ្នាំនេះដែរ ការធ្វើបង្ហាញអំពីការអនុវត្តការចិញ្ចឹមសត្វល្អ បានត្រូវជំរុញនៅទូទាំងប្រទេសជាមួយការរីកចម្រើនក្នុងការពង្រឹងចងក្រងសហគមន៍ចិញ្ចឹមសត្វ ដើម្បីងាយស្រួលក្នុងការផ្តល់ការគាំទ្រ និងលក់ផលិតផលជាលក្ខណៈប្រមូលផ្តុំ។

## IV. លទ្ធផលជំរុញផលិតកម្មសត្វ និងសុខភាពសត្វ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មានតួនាទីធានាការគ្រប់គ្រង និងអភិវឌ្ឍន៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ការពារសុខភាពសាធារណៈ សុខភាពសត្វ សុខុមាលភាពសត្វ និងការពារបរិស្ថាន បង្ការទប់ស្កាត់ លុបបំបាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វ ការពារធនធានសត្វ និងពូជសត្វរបស់ជាតិ ព្រមទាំងធានានូវនិរន្តរភាពនៃការផ្គត់ផ្គង់សត្វ និងផលិតផលសត្វ ប្រកបដោយគុណភាព និងសុវត្ថិភាពសម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ។

### ១-ការជំរុញការចិញ្ចឹមសត្វ និងបង្កើនផលិតភាពសត្វ

ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបសុសត្វឆ្នាំ២០១៦-២០២៥ គាំទ្រដល់អ្នកចិញ្ចឹមសត្វខ្នាតតូច និងជំរុញការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្ម តាមរយៈការកែលម្អការចិញ្ចឹមសត្វលក្ខណៈគ្រួសារ ជំរុញការកែលម្អពូជសត្វ ការបង្កាត់ពូជសត្វ និងផលិតកម្មចំណីសត្វ ការសម្របសម្រួល និងការជំរុញអនុវត្តការចិញ្ចឹមសត្វល្អ (GAHP) ការតាមដាន និងត្រួតពិនិត្យគុណភាពចំណីសត្វ ការគ្រប់គ្រងកាកសំណល់សត្វ ការពង្រឹងការគ្រប់គ្រងទិន្នន័យស្ថិតិផលិតកម្មសត្វ និងអត្តសញ្ញាណកម្មសត្វ ជំរុញការវិនិយោគបង្កើតកសិដ្ឋានចិញ្ចឹមសត្វ និងវិនិយោគលើការផលិតចំណីសត្វ ដោយបានផ្តល់ការគាំទ្រ និងបង្កបរិយាកាសអនុគ្រោះដល់ការវិនិយោគក្នុងឆ្នាំ២០១៨ រួមមាន៖

### ១.១.ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ

ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារសរុបក្នុងឆ្នាំ២០១៨ មានចំនួន៣៤.៣៣៩.៨១០ក្បាល ក្នុងនោះមានគោចំនួន២.៩១៧.៣០២ក្បាល ក្របីចំនួន៥០០.៧៧៨ក្បាល ជ្រូកចំនួន១.៩៣៤.៩១៧ក្បាល បក្សីចំនួន២៨.៩៥៦.៣៤២ក្បាល សេះចំនួន៤.២០៧ក្បាល ចៀមចំនួន៤៥៩ក្បាល ពពែចំនួន២៥.៧៤៧ក្បាល និងដំរីចំនួន៥៨ក្បាល (ឧបសម្ព័ន្ធទី១ ទី២ និងទី៣)។

បើប្រៀបធៀបឆ្នាំ២០១៧ ស្ថិតិសត្វសរុបថយចុះ០,៤% ក្នុងនោះគោ-ក្របីថយ១,២% ជ្រូកថយ១៧% ចំណែកបក្សីមានកំណើន១,១% (ឧបសម្ព័ន្ធទី៤)។

**តារាងស្ថិតិសត្វចិញ្ចឹមជាលក្ខណៈគ្រួសារពីឆ្នាំ២០១៤-២០១៨**

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៤-២០១៨) | | | | | ប្រៀបធៀបឆ្នាំ |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ២០១៧&២០១៨ |
| ១ | គោ | ៣.០៥៣.៤៨១ | ២.៩០៣.៤២០ | ២.៨៩៧.១២៦ | ២.៩៥១.៣៥៩ | ២.៩១៧.៣០២ | -១,២% |
| ២ | ក្របី | ៥៤១.៨២៧ | ៥០៦.១៦៥ | ៥២៣.៣២០ | ៥០៨.៤៥៨ | ៥០០.៧៧៨ | -១,៥% |
| ៣ | គោ-ក្របី | ៣.៥៩៥.៣០៨ | ៣.៤០៩.៥៨៥ | ៣.៤២០.៤៤៦ | ៣.៤៥៩.៨១៧ | ៣.៤១៨.០៨០ | -១,២% |
| ៤ | កម្លាំងអូសទាញ | ១.២៤៩.៨១៧ | ១.១៣២.០៩៧ | ១.០៥១.៦២៥ | ៩៣៥.២៣៩ | ៨៣៦.៣០១ | -១០,៦% |
| ៥ | ជ្រូក | ២.៣៦០.៨២៣ | ២.៣៥៧.៨៣៩ | ២.៣៧១.២៨៣ | ២.៣៣១.៥១២ | ១.៩៣៤.៩១៧ | -១៧,០% |
| ៦ | បក្សី | ២៥.៦៣០.០២៧ | ២៦.៦៨៨.៦៧៥ | ២៨.៤០២.៤៨៦ | ២៨.៦៥២.៤០៩ | ២៨.៩៥៦.៣៤២ | ១,១% |
| ៧ | សេះ | ៩.១៦១ | ៧.៦៣៧ | ៥.៦១០ | ៥.០៥៥ | ៤.២០៧ | -១៦,៨% |
| ៨ | ចៀម | ២៣៨ | ៣៧៨ | ៤០០ | ៤៦១ | ៤៥៩ | -០,៤% |
| ៩ | ពពែ | ១៨.២៥៦ | ២៣.៣២១ | ២២.៧១៩ | ២៨.៥៤២ | ២៥.៧៤៧ | -៩,៨% |
| ១០ | ដំរី | ៦៣ | ៦៤ | ៦៣ | ៦៣ | ៥៨ | -៧,៩% |
| **សរុប** | | **៣១.៦១៣.៨៧៦** | **៣២.៤៨៧.៤៩៩** | **៣៤.២២៣.០០៧** | **៣៤.៤៧៧.៨៥៩** | **៣៤.៣៣៩.៨១០** | -០,៤% |




## ១.២.ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្ម

សត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មសរុបក្នុងឆ្នាំ២០១៨ សរុបមានចំនួន១០.០៣៥.៥៨៥ក្បាល ក្នុងនោះគោ-ក្របីមានចំនួន១១.៤៤៩ក្បាល ជ្រូកមានចំនួន៨១២.៩៣៨ក្បាល បក្សីមានចំនួន៩.២១០.៤០៩ក្បាល សេះចំនួន៨៩ក្បាល និងពពែចំនួន៧០០ក្បាល (ឧបសម្ព័ន្ធទី៥)។

បើប្រៀបធៀបឆ្នាំ២០១៧ ការចិញ្ចឹមសត្វលក្ខណៈពាណិជ្ជកម្មមានការកើន២០,១% ក្នុងនោះជ្រូកកើន៩,៤% បក្សីកើន២១,៣%។ ដោយឡែកគោ-ក្របីថយចុះ៤៤,៣% (ឧបសម្ព័ន្ធទី៦)។

### ស្ថិតិសត្វចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៨

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៤-២០១៨) | | | | | ប្រៀបធៀបឆ្នាំ ២០១៧&២០១៨ |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | |
| ១ | គោ | ៦.៤៤៦ | ១៣.២៨៩ | ២៣.១៨៨ | ២០.៣៦៣ | ១១.២៣២ | -៤៤,៨% |
| ២ | ក្របី | ៣២ | ៦៣ | ១៩៤ | ១៩៨ | ២១៧ | ៩,៦% |
| ៣ | គោ-ក្របី | ៦.៤៧៨ | ១៣.៣៥២ | ២៣.៣៨២ | ២០.៥៦១ | ១១.៤៤៩ | -៤៤,៣% |
| ៤ | ជ្រូក | ៣៧៤.៨៩៤ | ៤១៦.៥២៥ | ៥៩៩.៣៤១ | ៧៤២.៧៧១ | ៨១២.៩៣៨ | ៩,៤% |
| ៥ | បក្សី | ៥.៩៥៣.៦៣០ | ៧.៨៣០.៣៩៨ | ៧.៣៣១.២៧៥ | ៧.៥៩២.៥៣០ | ៩.២១០.៤០៩ | ២១,៣% |
| ៦ | សេះ | ០ | ៥២ | ៦៤ | ៨២ | ៨៩ | ៨,៥% |
| ៧ | ចៀម | ០ | ៣១ | ៦៧ | ០ | ០ | ០% |
| ៨ | ពពែ | ០ | ៥.៥៤៧ | ៦.២៥៨ | ៣៦៥ | ៧០០ | ៩១,៨% |
| សរុប | | ៦.៣៣៥.០០២ | ៨.២៦៥.៩០៥ | ៧.៩៦០.៣៨៧ | ៨,៣៥៦,៣០៩ | ១០.០៣៥.៥៨៥ | ២០,១% |




## ១.៣. ស្ថិតិសត្វសរុបទូទាំងប្រទេស (លក្ខណៈគ្រួសារ និងពាណិជ្ជកម្ម)

ជារួមផលិតកម្មសត្វគ្រប់ប្រភេទក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ មានអត្រាកំណើនគួរឱ្យកត់សម្គាល់ គឺចាប់ ៣៧.៩៤៨.៨៧៨ក្បាល នៅឆ្នាំ២០១៤ កើនដល់៤៤.៣៧៥.៣៩៥ក្បាល នៅឆ្នាំ២០១៨។ ដោយឡែកក្នុងឆ្នាំ ២០១៨ ស្ថិតិសត្វសរុបមាន៤៤.៣៧៥.៣៩៥ក្បាល ក្នុងនោះមានគោចំនួន២.៩២៨.៥៣៤ក្បាល ក្របីចំនួន ៥០០.៩៩៥ក្បាល ជ្រូកចំនួន២.៧៤៧.៨៥៥ក្បាល បក្សីចំនួន៣៨.១៦៦.៧៥១ក្បាល សេះចំនួន៤.២៩៦ក្បាល ចៀមចំនួន៤៥៩ក្បាល ពពែចំនួន២៦.៤៤៧ក្បាល និងដំរី៥៨ក្បាល (ឧបសម្ព័ន្ធទី៧)។

បើប្រៀបធៀបទៅនឹងឆ្នាំ២០១៧ មានអត្រាកំណើន៣,៦% ក្នុងនោះបក្សីកើន៥,៣% ដោយឡែកគោ-ក្របី ថយចុះ១,៥% និងជ្រូកថយចុះ១០,៦% (ឧបសម្ព័ន្ធទី៨)។

### តារាងស្ថិតិសត្វចិញ្ចឹមជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្មពីឆ្នាំ២០១៤-២០១៨

| ល.រ | ប្រភេទសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៤-២០១៨) | | | | | ប្រៀបធៀបឆ្នាំ ២០១៧&២០១៨ |
|---|---|---|---|---|---|---|---|
| | | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | |
| ១ | គោ | ៣.០៥៩.៩២៧ | ២.៩១៦.៧០៩ | ២.៩២០.៣១៤ | ២.៩៧១.៧២២ | ២.៩២៨.៥៣៤ | -១,៥% |
| ២ | ក្របី | ៥៤១.៨៥៩ | ៥០៦.២២៨ | ៥២៣.៥១៤ | ៥០៨.៦៥៦ | ៥០០.៩៩៥ | -១,៥% |
| ៣ | គោ-ក្របី | ៣.៦០១.៧៨៦ | ៣.៤២២.៩៣៧ | ៣.៤៤៣.៨២៨ | ៣.៤៨០.៣៧៨ | ៣.៤២៩.៥២៩ | -១,៥% |
| ៤ | កម្លាំងអូសទាញ | ១.២៤៩.៨១៧ | ១.១៣២.០៩៧ | ១.០៥១.៦២៥ | ៩៣៥.២៣៩ | ៨៣៦.៣០១ | -១០,៦% |
| ៥ | ជ្រូក | ២.៧៣៥.៧១៧ | ២.៧៧៤.៣៦៤ | ២.៩៧០.៦២៤ | ៣.០៧៤.២៨៣ | ២.៧៤៧.៨៥៥ | -១០,៦% |
| ៦ | បក្សី | ៣១.៥៨៣.៦៥៧ | ៣៤.៥១៩.០៧៣ | ៣៥.៧៣៣.៧៦១ | ៣៦.២៤៤.៩៣៩ | ៣៨.១៦៦.៧៥១ | ៥,៣% |
| ៧ | សេះ | ៩.១៦១ | ៧.៦៨៩ | ៥.៦៧៤ | ៥.១៣៧ | ៤.២៩៦ | -១៦,៤% |
| ៨ | ចៀម | ២៣៨ | ៤០៩ | ៤៦៧ | ៤៦១ | ៤៥៩ | -០,៤% |
| ៩ | ពពែ | ១៨.២៥៦ | ២៨.៨៦៨ | ២៨.៩៧៧ | ២៨.៩០៧ | ២៦.៤៤៧ | -៨,៥% |
| ១០ | ដំរី | ៦៣ | ៦៤ | ៦៣ | ៦៣ | ៥៨ | -៧,៩% |
| សរុប | | ៣៧.៩៤៨.៨៧៨ | ៤៩.៧៥៣.៤០៤ | ៤២.១៨៣.៣៩៤ | ៤២.៨៣៤.១៦៨ | ៤៤.៣៧៥.៣៩៥ | ៣,៦% |




## ១.៤.ការប្រៀបធៀបបែបផែនផលិតកម្មតាមប្រភេទសត្វ

ការជំរុញផលិតកម្មសត្វ និងបង្កើនផលិតភាពសត្វជាគោលដៅអាទិភាពសម្រាប់ការធ្វើពាណិជ្ជកម្មសត្វ។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្ម មានអត្រាកើនឡើងគួរឱ្យកត់សម្គាល់ គឺកើនពី៦.៣៣៥.០០២ក្បាល នៅឆ្នាំ២០១៤ ឡើងដល់១០.០៣៥.៥៨៥ក្បាល នៅក្នុងឆ្នាំ២០១៨។ ដោយឡែកនៅក្នុងឆ្នាំ២០១៨នេះ ផលិតកម្មសត្វលក្ខណៈពាណិជ្ជកម្មមានកំណើន២៣% ក្នុងនោះផលិតកម្មជ្រូកលក្ខណៈពាណិជ្ជកម្មមានកំណើន៣០% និងផលិតកម្មបក្សីមានកំណើន២៤%។ អត្រានៃកំណើនផលិតសត្វជាលក្ខណៈពាណិជ្ជកម្មនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីការផ្លាស់ប្តូរបែបផែនផលិតកម្មសត្វជាវិជ្ជមានមួយ ដើម្បីឈានទៅកែលម្អផលិតភាពសត្វ និងប្រសិទ្ធភាពសេដ្ឋកិច្ចកាន់តែប្រសើរឡើង។

### តារាងស្ថិតិសត្វតាមបែបផែនផលិតកម្ម ពីឆ្នាំ២០១៤-២០១៨

| បែបផែន ផលិតកម្មសត្វ | ស្ថិតិសត្វ ៥ឆ្នាំចុងក្រោយ (២០១៤-២០១៨) | | | | | ប្រៀបធៀបឆ្នាំ ២០១៧ & ២០១៨ |
|---|---|---|---|---|---|---|
| | ឆ្នាំ២០១៤ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | |
| លក្ខណៈគ្រួសារ | ៣១.៦១៣.៨៧៦ | ៣២.៤៨៧.៤៩៩ | ៣៤.២២៣.០០៧ | ៣៤.៤៧៧.៨៥៩ | ៣៤.៣៣៩.៨១០ | -0,៤% |
| លក្ខណៈពាណិជ្ជកម្ម | ៦.៣៣៥.០០២ | ៨.២៦៥.៩០៥ | ៧.៩៦០.៣៨៧ | ៨.៣៥៦.៣០៩ | ១០.០៣៥.៥៨៥ | ២០,១% |
| សរុប | ៣៧.៩៤៨.៨៧៨ | ៤០.៧៥៣.៤០៤ | ៤២.១៨៣.៣៩៤ | ៤២.៨៣៤.១៦៨ | ៤៤.៣៧៥.៣៩៥ | ៣,៦% |

### ក្រាហ្វិកប្រៀបធៀបអត្រាតាមបែបផែនផលិតកម្មសត្វ ពីឆ្នាំ២០១៦-២០១៨



### ក្រាហ្វិកប្រៀបធៀបអត្រានៃផលិតកម្មជ្រូកពីឆ្នាំ២០១៦-២០១៨




### ក្រាហ្វិកប្រៀបធៀបអត្រានៃផលិតកម្មបក្សីពីឆ្នាំ២០១៦-២០១៨




## ១.៥. តម្រូវការសត្វ និងសាច់

ផ្អែកតាមរបាយការណ៍របស់អង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ ការបរិភោគសាច់សត្វនៅកម្ពុជាក្នុងមនុស្សម្នាក់ក្នុងមួយឆ្នាំហូបសាច់ជាមធ្យមប្រមាណ១៧,៦០គីឡូក្រាម ក្នុងនោះមានសាច់គោ-ក្របី៥គីឡូក្រាម សាច់ជ្រូក៩,២៩គីឡូក្រាម សាច់បក្សី៣,៣គីឡូក្រាម និងសាច់សត្វផ្សេងៗទៀត០,០១គីឡូក្រាម។ ដូចនេះនៅក្នុងឆ្នាំ២០១៨ ប្រជាជនកម្ពុជាបរិភោគសាច់សត្វសរុបប្រមាណ២៨៥.៤៣២តោន (១៦,២៤៥លាននាក់) ដោយមិនទាន់គិតពីភ្ញៀវទេសចរប្រមាណ៦លាននាក់។ ផលិតកម្មសត្វក្នុងស្រុកមានលទ្ធភាពអាចផ្គត់ផ្គង់សាច់បានប្រមាណ ២៣១.២៨៣តោន ឬស្មើនឹង៨១% ក្នុងនោះសាច់គោ-ក្របី៨៦.៧៧២តោន (៧៨៩ពាន់ក្បាល) សាច់ជ្រូក៩៩.៧៩៣តោន (១.៩៩៦ពាន់ក្បាល) និងសាច់បក្សី៤៤.៧១៨តោន (៣៧.២៦៥ពាន់ក្បាល)។ បរិមាណដែលខ្វះត្រូវបាននាំចូល ដើម្បីបំពេញតម្រូវការបន្ថែម ជាក់ស្តែងនៅក្នុងឆ្នាំ២០១៨ កម្ពុជាបាននាំចូលសាច់ និងផលិតសត្វសត្វមួយចំនួនមានជ្រូកសាច់រស់ចំនួន ៦៣០.៧៧៦ក្បាល និងមាន់រស់ចំនួន៣.៩៨១.៣០៣ក្បាល និងសាច់ចម្រុះចំនួន២.៤៤០,៧តោន (សាច់ជ្រូក មាន់ ទា ក្រួច សាច់គោក្របី ប្រហិត ប្រ៊ូម៉ា) (ឧបសម្ព័ន្ធទី៩ និង១០)។

### តារាងតម្រូវការប្រើប្រាស់ ការផ្គត់ផ្គង់ និងការបំពេញបន្ថែម ឆ្នាំ២០១៨

| ប្រភេទសត្វ | តម្រូវការប្រើប្រាស់ | | លទ្ធភាពផ្គត់ផ្គង់ក្នុងស្រុក | | តម្រូវការនាំចូល (ផែនការ) | |
|---|---|---|---|---|---|---|
| | តោន | ពាន់ក្បាល | តោន | ពាន់ក្បាល | តោន | ពាន់ក្បាល |
| គោ ក្របី | ៨១.០៨៩ | ៧៣៧ | ៨៦.៧៧២ | ៧៨៩ | -៥.៦៨៣ | -៥២ |
| ជ្រូក | ១៥០.៦៦២ | ៣.០១៣ | ៩៩.៧៩៣ | ១.៩៩៦ | ៥០.៨៧០ | ១.០១៧ |
| បក្សី | ៥៣.៥១៨ | ៤៤.៥៩៩ | ៤៤.៧១៨ | ៣៧.២៦៥ | ៨.៨០០ | ៧.៣៣៣ |
| ផ្សេងៗ | ១៦២ | ១៤ | - | - | ១៦២ | ១៤ |
| **សរុប** | **២៨៥.៤៣២** | | **២៣១.២៨៣** | - | **៥៤.១៤៩** | |

## ក្រាហ្វិកបង្ហាញពីតម្រូវការប្រើប្រាស់សាច់សរុបប្រចាំឆ្នាំ




## ក្រាហ្វិកបង្ហាញពីតម្រូវការសាច់ ការផ្គត់ផ្គង់ និងការនាំចូលបន្ថែម




## ១.៦. ការនាំចេញសត្វ និងផលិតផលសត្វ

កម្ពុជាមានលទ្ធភាពធ្វើការនាំចេញគោក្របី ជ្រូក មាន់ ស្វាក្ដាម សាច់ ផលិតផលសត្វ ចំណីសត្វ និងទឹកដោះគោមួយចំនួនទៅបរទេសផងដែរ។ សរុបក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ កម្ពុជាបាននាំចេញគោក្របីចំនួន៤៣.៧៥៧ក្បាល ជ្រូកពូជ (មេ,បា,កូន) ចំនួន១០៩.៨៣៨ក្បាល កូនមាន់ពូជចំនួន៥៦.០០០ក្បាល ស្វាក្ដាមចំនួន៧៧.៦៤៦ក្បាល ចំណីផ្អែចំនួន៧.០៦៣តោន ស្បែកគោក្របីប្រឡាក់អំបិលចំនួន១៨.៦០៤តោន និងទឹកដោះគោចំនួន៨.០០៩តោន។ ដោយឡែកនៅក្នុងឆ្នាំ២០១៨ បាននាំចេញគោក្របីចំនួន៦.៧៨៦ក្បាល ជ្រូកពូជចំនួន៥.៥០៥ក្បាល ស្វាក្ដាមចំនួន១០.៤៧២ក្បាល ស្បែកគោក្របីប្រឡាក់អំបិលចំនួន១.២៧៥តោន និងទឹកដោះគោចំនួន៧.៥៥៨តោន។

### តារាងស្ថិតិនាំចេញសត្វ សាច់ ផលិតផលសត្វ និងចំណីសត្វពីឆ្នាំ២០១៤-២០១៨

| ប្រភេទសត្វនិង ផលិតផលសត្វ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
|---|---|---|---|---|---|---|---|
| គោ ក្របី | ក្បាល | ១២.១៦១ | ៧.៣៣៥ | ៦.២៣៥ | ១១.២៤០ | ៦.៧៨៦ | ៤៣.៧៥៧ |
| ជ្រូកពូជ (មេ បា) | ក្បាល | ២.០១៧ | ២.០២១ | ១.២៥០ | ១.១៤០ | ៥០៥ | ៦.៩៣៣ |
| ជ្រូកពូជ (កូន) | ក្បាល | ៥០.៤០០ | ១៣.៣០៥ | ៣៤.២០០ | | ៥.០០០ | ១០២.៩០៥ |
| ស្វាក្តាម | ក្បាល | ៤.៥៣០ | ៤.១៨០ | ៥១.៥៣០ | ៦.៩៣៤ | ១០.៤៧២ | ៧៧.៦៤៦ |
| កូនមាន់ | ក្បាល | | | ៥៦.០០០ | | | ៥៦.០០០ |
| សាច់គោ | តោន | | | ៦៨ | ៧ | ១២ | ៨៧ |
| ទឹកដោះគោ | តោន | | | | ៤៥១ | ៧.៥៥៨ | ៨.០០៩ |
| ចំណីឆ្អែ | តោន | ១.១៨២ | ១.៦៥២ | ១.៣៧០ | ១.៣៦៥ | ១.៤៩៤ | ៧.០៦៣ |
| រោមសត្វ | តោន | ៦៣ | ៦៣ | ៥០ | ២៨ | ២៤ | ២២៨ |
| ស្បែកគោ ក្របី ជ្រូក | តោន | ១១.៦២០ | ២.២៥៤ | ១.៤៨៣ | ១.៩៧២ | ១.២៧៥ | ១៨.៦០៤ |

## ១.៧. កម្មវិធីកែលម្អពូជ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសបង្កាត់សិប្បនិម្មិតគោ និងជ្រូក ព្រមទាំងផ្សព្វផ្សាយបច្ចេកទេស និងផលប្រយោជន៍នៃការបង្កាត់សិប្បនិម្មិតគោ និងជ្រូកដល់មន្ត្រីជំនាញផលិតកម្មនិងបសុព្យាបាលទាំង២៥រាជធានី-ខេត្ត។ តាមរយៈការអនុវត្តកម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាបន្នអនុវិស័យវិស័យផលិតកម្មសត្វ បានបង្កើតមជ្ឈមណ្ឌល និងកន្លែងបង្កាត់សិប្បនិម្មិតគោបានចំនួន១១កន្លែង នៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ ស្ទឹងត្រែង ស្វាយរៀង តាកែវ និងខេត្តឧត្តរមានជ័យ ព្រមទាំងមជ្ឈមណ្ឌល និងកន្លែងបង្កាត់សិប្បនិម្មិតជ្រូក១២កន្លែង នៅក្នុងខេត្តចំនួន១១ គឺខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ព្រៃវែង ស្ទឹងត្រែង ស្វាយរៀង តាកែវ ឧត្តរមានជ័យ ត្បូងឃ្មុំ និងសាកលវិទ្យាល័យភូមិន្ទកសិកម្ម។

នៅឆ្នាំ២០១៨នេះ បង្កាត់ពូជសិប្បនិម្មិតគោបានចំនួន៧៩៨ក្បាល បង្កើតបានកូនគោចំនួន៣២៤ក្បាល (ញី១៨៦ក្បាល) និងបង្កាត់សិប្បនិម្មិតជ្រូកបានចំនួន៩.១២៥ក្បាល បង្កើតកូនជ្រូកបានចំនួន១៨.៩៦៧ក្បាល (ញី ៩.៣០៦ក្បាល)។ ជាការកត់សម្គាល់ពិនិត្យឃើញថា ពូជជ្រូកត្រូវបានកែលម្អយ៉ាងឆាប់រហ័យនៅទូទាំងប្រទេស (ឧបសម្ព័ន្ធទី១១)។

## ១.៨. អំពីចំណីសត្វ

ការងារចំបងគឺការរៀបចំកម្មវិធីកែលម្អចំណីសត្វ ផ្សព្វផ្សាយពូជស្មៅ ដែលសំបូរទៅដោយសារធាតុចិញ្ចឹម និងផ្តល់ទិន្នផលខ្ពស់។ បច្ចុប្បន្នបានពង្រីកកម្មវិធីដំណាំចំណីសត្វនៅទូទាំង២៥ រាជធានី-ខេត្ត សរុបមានកន្លែងធ្វើបង្ហាញចំនួន១.១១៨កន្លែង លើផ្ទៃដីចំនួន១០.៧០៦ហិកតា (ឧបសម្ព័ន្ធទី១២)។

បច្ចុប្បន្នមានក្រុមហ៊ុន និងសហគ្រាសដែលបានវិនិយោគសាងសង់រោងចក្រផលិតចំណីសត្វ នៅក្នុងប្រទេសកម្ពុជាមានចំនួន១៦ក្រុមហ៊ុន ក្នុងនោះមានក្រុមហ៊ុន ស៊ីភី (ខេមបូឌា) អេហ្វ្រីម៉ាស្ទ័រ ហ្វ្រីនហ្វីត បេតាហ្គ្រោ ញ៉ូវហូប ស៊ីជេ អ៊ីស្តហូប សាណាហ្គ្រូ អិមភិក.អេស៊ីអិមស៊ី ស៊ុំខេវ៉ាយអ៊ី អិលវីអេស វើលដ៍វេត ពេជ្រមុន្នី ភីដិបបែលយូអ ដីហ្សែរ និងក្រុមហ៊ុនអេអែនឌី ហ្វីដ សរុបរោងចក្រផលិតចំណីសត្វទាំងអស់មានចំនួន១៨កន្លែង ដែលមានសមត្ថភាពអាចផលិតចំណីសត្វបានប្រមាណ២លានតោន/ឆ្នាំ។ នៅក្នុងឆ្នាំ២០១៨នេះ ក្រុមហ៊ុនដែលបាននឹងកំពុងដំណើរការផលិតចំណីសត្វយ៉ាងសកម្មមានចំនួន១៥ក្រុមហ៊ុន និងរោងចក្រផលិតចំណីសត្វចំនួន១៧កន្លែង ផលិតចំណីសត្វបានប្រមាណ

១,០៦លានតោន ស្មើនឹង៥០% នៃសមត្ថភាពផលិតរបស់រោងចក្រ (ឧបសម្ព័ន្ធទី១៣ និង១៤) និងត្រូវការនាំចូលបន្ថែមនូវចំណីសត្វ១១០.៤៧៩តោន សារធាតុបន្ថែម១៦.៩៥៨តោន វត្ថុធាតុដើម២៤៥.៧១០តោន បសុឱសថ ១.៣៥៦តោន វ៉ាក់សាំង១៤៥តោន សម្ភារបសុពេទ្យ២០តោន និងឧបករណ៍ចិញ្ចឹមសត្វ២.៥០៥តោន។

### ១.៩. ការគ្រប់គ្រងកាកសំណល់សត្វ

ការសាងសង់ឡជីវឧស្ម័ន ត្រូវបានជំរុញ និងលើកទឹកចិត្តឱ្យសាងសង់យ៉ាងទូលំទូលាយ ដើម្បីគ្រប់គ្រងកាកសំណល់សត្វ ដោយបានទាញយកនូវថាមពលកកើតឡើងវិញ និងផ្តល់នូវជីធម្មជាតិ។ រហូតមកដល់បច្ចុប្បន្ននេះ ឡជីវឧស្ម័នគ្រួសារសាងសង់បានចំនួន២៧.២៣៣ឡ ក្នុងខេត្តចំនួន១៣ គឺខេត្តបាត់ដំបង កំពង់ចាម កំពង់ឆ្នាំង កណ្តាល កំពត កំពង់ស្ពឺ កំពង់ធំ ពោធិ៍សាត់ ព្រៃវែង សៀមរាប ស្វាយរៀង ត្បូងឃ្មុំ និងខេត្តតាកែវ។ ដោយឡែកក្នុងឆ្នាំ២០១៨នេះ ឡជីវឧស្ម័នគ្រួសារសាងសង់បានចំនួន៦៤៦ឡ។







## ២- ការលើកកម្ពស់សុខភាពសត្វ និងសុខភាពសាធារណៈ:

សកម្មភាពសំខាន់ៗក្នុងផ្នែកនេះ គឺការពង្រឹងសុខភាពសត្វ និងអនាម័យសត្វ សាច់ ដែលផ្តោតសំខាន់លើការត្រួតពិនិត្យអនាម័យ គុណភាព សុវត្ថិភាព ពង្រឹងការផ្តល់សេវាកម្មបសុពេទ្យ កាត់បន្ថយការឆ្លងរាលដាលជំងឺសត្វ និងការផ្គត់ផ្គង់សាច់ប្រកបដោយគុណភាពនៅលើទីផ្សារ ដើម្បីការពារសុខភាពសាធារណៈ និងសុវត្ថិភាពម្ហូបអាហារ។

## ២.១. ការលើកកម្ពស់សុខភាពសត្វ

នៅឆ្នាំ២០១៨នេះ គណៈកម្មការគ្រប់គ្រង និងវាយតម្លៃហានិភ័យសុខភាពសត្វ និងផលិតកម្មសត្វនៃអគ្គ-នាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានពង្រឹងសកម្មភាពត្រួតពិនិត្យ និងទប់ស្កាត់បទល្មើសចលនាសត្វ និងការធ្វើអាជីវកម្មសត្វ ដោយបានសហការជាមួយការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី-ខេត្ត និងសមត្ថកិច្ចពាក់ព័ន្ធ ដោយបន្តអនុវត្តសេចក្ដីណែនាំអំពីលក្ខខណ្ឌតម្រូវសម្រាប់ការនាំចូលសត្វ និងផលិតផលសត្វ។ ជាលទ្ធផលក្នុងរយៈពេលមួយឆ្នាំនេះ នៅទូទាំងប្រទេសបានធ្វើការត្រួតពិនិត្យចលនាសត្វ និងផលិតផលសត្វចំនួន៣៥៨ករណី និងបានបង្ក្រាបបទល្មើសចលនាសត្វ និងផលិតផលសត្វបានចំនួន១៦ករណី (ដឹកជញ្ជូនមាន់រស់៨ករណី ជ្រូករស់៤ករណី ពពែ១ករណី ទារស់១ករណី ប្រហិត១ករណី និងចំណីគោ១ករណី)។ ជាមួយគ្នានេះដែរ ធ្វើការអង្កេតតាមដាន បង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងជំងឺឆ្លងសត្វ ព្រមទាំងបានរៀបចំប្រព័ន្ធព័ត៌មាន និងរាយការណ៍ជំងឺឆ្លងសត្វទាំងថ្នាក់ជាតិ និងអន្តរជាតិ ចាត់វិធានការណ៍ជីវសុវត្ថិភាព និងកម្មវិធីឆ្លើយតបបន្ទាន់ករណីផ្ទុះជំងឺឆ្លងសត្វ។ លទ្ធផលសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០១៨ រួមមាន៖

១. ចាក់វ៉ាក់សាំងការពារជំងឺឆ្លងសំខាន់ៗដែលកើតមានលើគោ ក្របី ពពែ ចៀម ដូចជាជំងឺអុតក្តាម បូសខ្យល់ និងសារទឹកបានសរុបចំនួន១,៥៧១,២០២ក្បាល ចាក់វ៉ាក់សាំងការពារជំងឺឆ្លងលើជ្រូកចំនួន១,៤៧៩,២១៦ក្បាល ចាក់វាក់សាំងការពារជំងឺឆ្លងបក្សីបានចំនួន៧,៨១២,៩០៨ក្បាល និងចាក់វ៉ាក់សាំងការពារជំងឺឆ្លងឆ្កែ និងឆ្មាចំនួន៧,០៣០ក្បាល (ឧបសម្ព័ន្ធទី១៥ និង១៦) ។

២.ចាត់វិធានការជីវសុវត្ថិភាព ផ្សព្វផ្សាយ និងអនុវត្តផ្ទាល់នៅសត្តឃាតដ្ឋាន កសិដ្ឋានចិញ្ចឹមសត្វ ពេលដឹកជញ្ជូនសត្វ និងផលិតផលសត្វ ទីកន្លែងផ្ទុះជំងឺសត្វសរុបចំនួន៥៨,២២៧លើក (ឧបសម្ព័ន្ធទី១៧)

៣.ក្នុងឆ្នាំ២០១៨ ភ្នាក់ងារសុខភាពសត្វភូមិទូទាំងប្រទេសមានចំនួន១១.៧៨៦នាក់ បានបណ្ដុះបណ្ដាលចំនួន៩៧៥នាក់ (ឧបសម្ព័ន្ធទី១៨)។

## ២.២. ការពង្រឹងសុខភាពសាធារណៈបសុព្យាបាល

សុខភាពសាធារណៈបសុព្យាបាលជាផ្នែកមួយ មានភារៈកិច្ចវាយតម្លៃ ផ្ដល់ការអនុញ្ញាតបង្កើតសត្តឃាតដ្ឋាន និងកន្លែងកែច្នៃសាច់ និងផលិតផលសត្វ ដើម្បីធានាសុខភាពសាធារណៈ តាមរយៈការពង្រឹងការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ ដោយបង្កើនសមត្ថភាពមន្ត្រី និងផ្សព្វផ្សាយដល់អាជីវករពាក់ព័ន្ធលើការអនុវត្តវិធានអនាម័យសត្វ សាច់ និងផលិតផលសត្វ។ នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាលបានសហការជាមួយការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី-ខេត្ត ចុះផ្សព្វផ្សាយច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ អនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់ និងផលិតផលសត្វ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់ខ្ពស់ រៀបចំចងក្រងឯកសារបច្ចេកទេសនានា និងផ្ដល់ការបណ្ដុះបណ្ដាលបច្ចេកទេសពាក់ព័ន្ធនឹងការធ្វើអាជីវកម្មសត្វ ផលិតផលសត្វ ការពិឃាតតាមបច្ចេកទេសដល់អ្នកពាក់ព័ន្ធ ព្រមទាំងបានបំពាក់បំប៉ន បង្កើនសមត្ថភាពដល់មន្ត្រីប្រចាំការនៅតាមសត្តឃាតដ្ឋាន និងអ្នកពាក់ព័ន្ធលើជំនាញត្រួតពិនិត្យសុខភាពសត្វ អនាម័យសាច់ និងផលិតផលសត្វចំនួន១៩៧នាក់ បានបណ្ដុះបណ្ដាលបច្ចេកទេសស្ដីពីការពិឃាតសត្វជ្រូក គោ ក្របី ប្រកបដោយមនុស្សធម៌ចំនួន៩វគ្គ មានអ្នកចូលរួមសរុបចំនួន២៦៦នាក់ មានស្ត្រីចំនួន៥៦នាក់។

គិតមកដល់ដំណាច់ឆ្នាំ២០១៨នេះ នៅទូទាំងប្រទេសសត្តឃាតដ្ឋានអនុវត្តតាមច្បាប់ និងបទដ្ឋានបច្ចេកទេសបានកើនដល់១៧៥ ក្នុងនោះមានសត្តឃាតដ្ឋានវិនិយោគចំនួន៣១កន្លែង សត្តឃាតដ្ឋានគោទំនើបលំដាប់អន្តរជាតិនៅខេត្តព្រះសីហនុចំនួន១កន្លែង និងសត្តឃាតដ្ឋានបក្សីទំនើបនៅខេត្តកណ្ដាលចំនួន១កន្លែង។ ថ្វីបើសត្តឃាតដ្ឋាន

កើនជាលំដាប់ ប៉ុន្តែចំនួននេះមិនទាន់គ្រប់គ្រាន់ទាំងបរិមាណ និងមិនអនុលោមតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការបង្កើត និងគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសាច់ និងផលិតផលសត្វនៅឡើយ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ នឹងខិតខំណែនាំបច្ចេកទេសអនាម័យសត្តឃាតដ្ឋាន អនាម័យសាច់ និងអនាម័យដឹកជញ្ជូនសាច់បន្ថែមទៀត (ឧបសម្ព័ន្ធទី១៩)។

## ៣- ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល និងនីតិកម្ម

### ៣.១. ការងារផ្សព្វផ្សាយបច្ចេកទេស

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំកម្មវិធីផ្សព្វផ្សាយ សំភាសន៍ វេទិកាសាធារណៈជាមួយអ្នកពាក់ព័ន្ធលើប្រធានបទសំខាន់ៗ និងបានផ្សព្វផ្សាយឯកសារបទសម្ភាសន៍ វីដេអូអប់រំបច្ចេកទេសផលិតកម្ម និងបសុព្យាបាល ច្បាប់ បទដ្ឋានគតិយុត្ត ព័ត៌មាន សេចក្តីណែនាំ សារាចរ ប្រកាស និងឯកសារពាក់ព័ន្ធនានាតាមវិទ្យុ ទូរទស្សន៍ គេហទំព័រ និងតាមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងចែកជូនតាមបណ្តារាជធានី-ខេត្តទាំង ២៥ ព្រមទាំងបានផលិតឯកសារបង្ហាញពីការចិញ្ចឹមសត្វ និងការដាំដំណាំចំណីសត្វ។ លទ្ធផលការងារផ្សព្វផ្សាយបច្ចេកទេសរួមមានដូចខាងក្រោម៖

១.បណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមសត្វ និងជំងឺឆ្លងសត្វ ដល់កសិករចិញ្ចឹមសត្វ និងអ្នកពាក់ពន្ធ័ចំនួន ៦លើក ដោយមានអ្នកចូលរួមសរុបចំនួន១៥០នាក់ ក្នុងនោះមានស្ត្រីចំនួន៧៨នាក់។

២.គាំទ្រដល់សហគមន៍ចិញ្ចឹមសត្វចំនួន៦ ក្នុងខេត្តចំនួន៦ ក្នុងគោលបំណងលើកស្ទួយជីវភាពរស់នៅរបស់កសិករតាមរយៈវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមសត្វ ក្នុងនោះមានអ្នកចូលរួមសរុបចំនួន១៨៤នាក់ ស្រី ១០៧នាក់។

៣.បណ្តុះបណ្តាលស្តីពីបច្ចេកទេសដាំដំណាំចំណីសត្វចំនួន៣២វគ្គ ដោយមានកសិករចូលរួមចំនួន៨៥៤នាក់ ក្នុងនោះស្ត្រីចំនួន៤០៣នាក់។

៤.ប្រជុំផ្សព្វផ្សាយ និងឃោសនាស្តីពីជំងឺឆ្លងសត្វ និងជីវសុវត្ថិភាពចំនួន៤២លើក ដល់កសិករចំនួន១៥៤៣ នាក់ ក្នុងនោះស្ត្រីចំនួន៧៣៥។

### ៣.២. ការងារនីតិកម្ម

ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការកាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ ២០១៦ ដើម្បីធានាការគ្រប់គ្រង ការអភិវឌ្ឍន៍សុខភាពសត្វនិងផលិតកម្មសត្វ ការពារសុខភាពមនុស្ស សុខភាពសត្វ សុខុមាលភាពនិងការពារបរិស្ថាន បង្ការទប់ស្កាត់និងលុបបំបាត់ការឆ្លងរាលដាលជំងឺសត្វ ធានានិរន្តរភាពនៃការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយគុណភាពនិងសុវត្ថិភាពសម្រាប់ទីផ្សារក្នុងស្រុក និងការនាំចេញ។ មន្ត្រីជំនាញបានផ្សព្វផ្សាយច្បាប់ និងបទដ្ឋានគតិយុត្តដល់អ្នកពាក់ព័ន្ធក្នុងខេត្តចំនួន១១ ដែលមានអ្នកចូលរួមសរុបចំនួន៥៣០នាក់ និងចុះអធិការកិច្ចនៅកន្លែងតាំងលក់ចំណីសត្វ និងបសុឱសថនៅតាមបណ្តារាជធានី-ខេត្តចំនួន៩លើក។

លើសពីនេះទៀត អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននឹងកំពុងរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់សំខាន់ៗចំនួន១៨ ដែលក្នុងនោះមានលិខិតបទដ្ឋានក្រោមច្បាប់មួយចំនួនត្រូវបានរៀបចំរួចរាល់ និងមួយចំនួនទៀតកំពុងស្ថិតក្នុងដំណើរការរៀបចំ និងបន្តពិភាក្សារួមមាន៖

#### ក. លិខិតបទដ្ឋានគតិយុត្តដែលបានរៀបចំរួចរាល់

១. ប្រកាសស្តីពីនីតិវិធី និងការតម្រូវការបមាណីយសម្រាប់ចុះបញ្ជីបសុឱសថ

២. ប្រកាសស្តីពីនីតិវីធីនិងការតម្រូវបមាណីយសម្រាប់ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម

៣.ប្រកាសស្តីពីចំណាត់ថ្នាក់ខ្នាត បទដ្ឋានបច្ចេកទេស និងនីតិវិធីសម្រាប់ការផ្តល់លិខិតអនុញ្ញាត ការចិញ្ចឹមសត្វនិងការបង្កាត់ពូជសត្វ។

បន្ទាប់ពីប្រកាសខាងលើចូលជាធរមាន មានក្រុមហ៊ុនចំនួន២០ បានចុះបញ្ជីចំណីសត្វចំនួន៤៨០មុខ សារធាតុបន្ថែម១៥៧មុខ និងវត្ថុធាតុដើម១០មុខ និងក្រុមហ៊ុនចំនួន៨ បានចុះបញ្ជីបសុឱសថចំនួន៤១៤មុខ វ៉ាក់សាំង១៥៧មុខ និងសារធាតុសកម្ម២០មុខ។

## ខ.លិខិតបទដ្ឋានគតិយុត្តដែលកំពុងពិនិត្យ បន្តការរៀបចំ និងពិភាក្សា

១. ព្រះរាជក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈបសុពេទ្យ

២. អនុក្រឹត្យស្ដីពីឯកសណ្ឋានសញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតផលសត្វ

៣. អនុក្រឹត្យស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ និងទីកន្លែងកែច្នៃបឋមផលិតផលសត្វ

៤. ប្រកាសស្ដីពីនីតិវិធីនៃការជ្រើសរើស ការបណ្ដុះបណ្ដាល ការគ្រប់គ្រងឱ្យមាននិរន្តរភាព និងភារកិច្ចភ្នាក់ងារសុខភាពសត្វភូមិ

៥. ប្រកាសស្ដីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិតលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំលក់រាយ និងដឹកជញ្ជូនបសុឱសថ

៦. សេចក្ដីព្រាងគោលការណ៍ណែនាំស្ដីពីគំរូសៀវភៅកំណត់ត្រាប្រតិបត្តិការបសុឱសថ និងចំណីសត្វ

៧. ប្រកាសស្ដីពីនីតិវិធីនៃការគ្រប់គ្រងបសុឱសថ និងវត្ថុធាតុជីវៈបសុព្យាបាលដែលធ្វើពាណិជ្ជកម្ម និងធ្វើការផលិតលាយផ្សំ

៨. ប្រកាសអន្តរក្រសួងស្ដីពីការផ្ដល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌

៩. សេចក្ដីសម្រេចស្ដីពីការតែងតាំងមន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ

១០. ប្រកាសស្ដីពីនីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

១១. ប្រកាសស្ដីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត និងបទដ្ឋានបច្ចេកទេសនៃការនាំចូល ការនាំចេញ ការនាំឆ្លងកាត់ ការផលិតលាយផ្សំ ការវេចខ្ចប់ជាថ្មី ការធ្វើសន្និធិ ការផ្គត់ផ្គង់ចែកចាយ ការលក់ដុំ និងការលក់រាយ និងដឹកជញ្ជូនចំណីសត្វ

១២. ប្រកាសស្ដីពីនីតិវិធីនៃការគ្រប់គ្រងចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម និងធ្វើការផលិតលាយផ្សំ

១៣. ប្រកាសស្ដីពីនីតិវិធីក្នុងការត្រួតពិនិត្យនូវបសុឱសថ ចំណីសត្វ និងវត្ថុធាតុដើម ឬសារធាតុសកម្ម ឬសារធាតុបន្ថែមដែលនាំចេញ នាំចូល ផលិតលាយផ្សំ និងវេចខ្ចប់ជាថ្មី

១៤. ប្រកាសអន្តរក្រសួងស្ដីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងយុត្តិធម៌

១៥. ប្រកាសស្ដីពីនីតិវិធីនៃការចេញលិខិតអនុញ្ញាត វិញ្ញាបនបត្របសុព្យាបាល និងបទដ្ឋានបច្ចេកទេសបសុព្យាបាលសម្រាប់ចរាចរណ៍សត្វ និងផលិតផលសត្វ។

## ៤.ការងារស្រាវជ្រាវ និងអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ

### ៤.១.ការងារស្រាវជ្រាវសុខភាពសត្វ

បច្ចុប្បន្នវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថភាពធ្វើរោគវិនិច្ឆ័យរកមេរោគបង្កជំងឺឆ្លងសត្វសំខាន់ៗ វិភាគចំណីសត្វ កាកសំណល់បសុឱសថ និងបណ្តុះបណ្តាលមន្ត្រីជំនាញលើការងារស្រាវ-ជ្រាវ។

#### ក.ធ្វើរោគវិនិច្ឆ័យជំងឺសត្វ

- លើបក្សីៈ ជំងឺផ្តាសាយបក្សី ជំងឺញូវកាសបក្សី ជំងឺប៉េស្តទា ជំងឺអាសន្នរោគ
- លើជ្រូកៈ ជំងឺប៉េសជ្រូក ជំងឺជ្រូកត្រចៀកខៀវ ជំងឺសាល់ម៉ូណែលឡូស៊ីស ជំងឺប៉េស្តជ្រូកអាហ្វ្រិក
- លើគោ ក្របីៈ ជំងឺសារទឹក ជំងឺអុតក្តាម ជំងឺបូសខ្យល់ ជំងឺឈាមខ្មៅ
- លើសត្វឆ្កែ ឆ្មាៈ ជំងឺឆ្កែឆ្កួត ជំងឺឡិបតូស្ពីរ៉ូស៊ីស
- លើសត្វស្វាៈ ជំងឺសាល់ម៉ូណែលឡូស ជំងឺស៊ីហ្គែលឡា ជំងឺបង្កដោយអីកូលី
- ជំងឺបណ្តាលមកពីចំណីអាហារ (សាច់ និងផលិតផលសាច់សត្វ ចំណីសត្វ ទឹកដោះគោ ស្បែកគោ)
- ជំងឺបង្កដោយប៉ារ៉ាស៊ីតនៅលើសត្វចិញ្ចឹម។

ឆ្នាំ២០១៨ វិទ្យាស្ថានបានយកវត្ថុវិភាគមកធ្វើរោគវិនិច្ឆ័យជំងឺសរុបចំនួន១៣.៤១៨ វត្ថុវិភាគ ក្នុងនោះរកឃើញវត្តមានជំងឺផ្តាសាយបក្សីចំនួន៧ករណី និងមានអនុប្រភេទផ្សេងទៀតH9N7។ លើសពីនេះទៀត វិទ្យាស្ថានបានអង្កេតតាមដានជំងឺផ្តាសាយបក្សីនៅទីផ្សារបក្សីរស់ក្នុងខេត្តចំនួន៦ (ភ្នំពេញ ខេត្តបាត់ដំបង កំពង់ចាម កំពត ព្រៃវែង និងខេត្តស្វាយរៀង)។

#### ខ. វិភាគចំណីសត្វ

វិទ្យាស្ថានមានលទ្ធភាពវិភាគគុណភាពចំណីសត្វ និងវត្ថុធាតុដើមផ្សំចំណីសត្វ ដោយពិនិត្យទៅលើលើប៉ារ៉ាម៉ែតសំខាន់ៗមួយចំនួនដូចជា ប្រូតេអ៊ីន ខ្លាញ់ ផូស្វរ សារធាតុសសៃរ សំណើម ផេះ និងជាតិម្សៅ។ ដោយឡែកវត្ថុធាតុដើមផ្សំចំណីសត្វមួយចំនួន វិទ្យាស្ថានមិនទាន់អាចវិភាគបាននៅឡើយ ដោយសារលក្ខណៈស៊ាំញាំរបស់វា និងទាមទារឧបករណ៍វិភាគផ្សេងទៀត។ វិទ្យាស្ថានកំពុងត្រៀមរៀបចំមន្ទីរពិសោធន៍គីមីបន្ថែមទៀតដើម្បីបំពេញចំណុចខ្វះខាតនេះ។

#### គ. ភាពស៊ាំបសុឱសថប្រឆាំងនឹងមេរោគ

ភាពស៊ាំនឹងឱសថប្រឆាំងនឹងមេរោគកំពុងចោទជាបញ្ហាដល់សុខភាពមនុស្ស សត្វ និងបរិស្ថាននៅក្នុងប្រទេសជាច្រើននៅលើពិភពលោក។ ការប្រើប្រាស់អង់ទីប៊ីយ៉ូទិកនៅក្នុងការចិញ្ចឹមសត្វនៅកម្ពុជា អាចនាំទៅរកភាពស៊ាំនឹងឱសថ ដោយសារមិនមានការគ្រប់គ្រងច្បាស់លាស់លើបសុឱសថ។ ឆ្លើយតបទៅនឹងបញ្ហានេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននឹងកំពុងរៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងការគ្រប់គ្រងការប្រើប្រាស់បសុឱសថក្នុងផលិតកម្មសត្វ ក៏ដូចជាគោលការណ៍ណែនាំផ្នែកបច្ចេកទេស ដើម្បីបញ្ចៀសហានីភ័យដែលអាចកើតមានតាមរយៈការប្រើប្រាស់ឱសថក្នុងផលិតកម្មសត្វ។ វិទ្យាស្ថានក៏បានធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពនៃភាពស៊ាំនឹងបសុឱសថនៅកម្ពុជា ដោយប្រមូលយកវត្ថុវិភាគសាច់គោ សាច់ជ្រូក និងខ្ទែងពោះវៀនមាន់ពីសត្តឃាតដ្ឋានពីខេត្តចំនួន១៥។ ជាលទ្ធផលនៃការវិភាគបង្ហាញថា មានវត្តមាន បាក់តេរីសាល់ម៉ូណែលឡា និងអីគូលីត្រូវបានរកឃើញនៅលើសាច់ និងខ្ទែងពោះវៀន ដែលមានភាពស៊ាំទៅនឹងអង់ទីប៊ីយ៉ូទិកជាច្រើនប្រភេទ។ វត្តមានបាក់តេរីសាល់ម៉ូណែលឡា និងអីគូលីត្រូវបានរកឃើញនេះ បណ្តាលមកពីការកង្វះអនាម័យនៅសត្តឃាតដ្ឋាន អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានណែនាំដល់បណ្តារាជធានី-ខេត្ត បន្តខិតខំអនុវត្តវិធានការអនាម័យឱ្យកាន់តែល្អប្រសើរនៅតាមសត្តឃាតដ្ឋានបន្ថែមទៀត។

### ឃ. វិភាគកាកសំណល់បសុឱសថ

បន្ទាប់ពីឧបករណ៍ UPLC-MS MS ត្រូវបានតម្លើងរួចរាល់នៅដើមឆ្នាំ២០១៨ វិទ្យាស្ថានបានទទួលជំនាញការមកបណ្ដុះបណ្ដាលមន្ត្រីមន្ទីរពិសោធន៍បសុឱសថ និងកាកសំណល់បសុឱសថ និងមន្ទីរពិសោធន៍ជីវគីមី និងវិសសាស្ត្រ ចំនួនពីរលើក និងបានបញ្ជូនមន្ត្រីទៅចូលរួមវគ្គបណ្ដុះបណ្ដាលនៅប្រទេសថៃឡង់ដ៍ចំនួនមួយលើក លើការប្រើប្រាស់ឧបករណ៍ និងការវិភាគរកកាកសំណល់បសុឱសថនៅក្នុងសាច់។ បច្ចុប្បន្នវិទ្យាស្ថានអាចវិភាគរកកាកសំណល់បសុឱសថមួយចំនួន ប៉ុន្តែមិនទាន់រលូននៅឡើយទេ ដោយសារខ្វះខាតសារធាតុគីមី និងសម្ភារឧបករណ៍មួយចំនួនទៀត ដើម្បីជំរុញដំណើរការវិភាគនេះ។

វិទ្យាស្ថានបានបង្កើនសមត្ថភាពដល់មន្ត្រីជំនាញតាមរយៈការបណ្ដុះបណ្ដាលស្ដីពីវិធីសាស្ត្រស្រាវជ្រាវចំនួន ៣៨៦រូប និងអង្កេត តាមដាន ស្រាវជ្រាវជំងឺចំនួន៩៣រូប ធ្វើរោគវិនិច្ឆ័យចំនួន១២រូប វិភាគអេពីដេមីសាស្ត្រក្នុងការបង្ការនិងទប់ស្កាត់ជំងឺចំនួន១៥៥រូប និងបង្កាត់សិប្បនិម្មិតចំនួន៣០នាក់។

**៤.២.ការងារស្រាវជ្រាវផលិតកម្មសត្វ៖** វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ បានសិក្សាស្រាវជ្រាវពូជសត្វល្អៗ ដែលមានស្រាប់ក្នុងស្រុក ដើម្បីផលិតមេជីវិត ធ្វើការបង្កក ពិនិត្យគុណភាព បង្កាត់សិប្បនិម្មិត ដើម្បីកាត់បន្ថយការនាំចូលមេជិវិតបង្កកពីបរទេស។ នៅឆ្នាំ២០១៨នេះ វិទ្យាស្ថានបានផលិតទឹកមេជីវិតគោបង្កកចំនួន១.៩៨០កម្រិត និងបានធ្វើការចែកទៅតាមបណ្ដាខេត្តនានាចំនួន៣.៦៤០កម្រិត ក្នុងនោះខេត្តឧត្តរមានជ័យ ១.៥០០កម្រិត ព្រៃវែង១.៣០០កម្រិត ពោធិ៍សាត់២៥០កម្រិត កំពង់ឆ្នាំង២៥០កម្រិត ស្ថានីយចិញ្ចឹមគោពូជភ្នំតាម៉ៅ ១០០កម្រិត តាកែវ៨០កម្រិត កំពង់ចាម៤០កម្រិត និងខេត្តបន្ទាយមានជ័យ២០កម្រិត។

នៅឆ្នាំ២០១៨នេះ បង្កាត់សិប្បនិម្មិតគោបាន៥២ក្បាល និងបង្កើតកូនគោបាន៣៨ក្បាល។ ជាការកត់សម្គាល់ ពូជជ្រូកបានត្រូវកែលម្អបានយ៉ាងឆាប់រហ័សនៅទូទាំងប្រទេស។

## ៥.ការងារពង្រឹងសមត្ថភាពអង្គភាព សេវាគាំទ្រ និងការអភិវឌ្ឍន៍ធនធានមនុស្ស

### ៥.១. ការពង្រឹងការគ្រប់គ្រងអង្គភាព

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងការតែងតាំង ផ្ទេរ និងប្រគល់ភារកិច្ចថ្នាក់ដឹកនាំជាមួយនឹងការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋាន វិទ្យាស្ថាន ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ មន្ទីរពិសោធន៍ និងស្ថានីយចិញ្ចឹមពូជសត្វ បានចប់សព្វគ្រប់ស្របតាមលិខិតបទដ្ឋានគតិយុត្តនានា ដែលមាននាយកដ្ឋានចំនួន៤ និងវិទ្យាស្ថាន១គឺ នាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការ នាយកដ្ឋានផលិតកម្មសត្វ នាយកដ្ឋានសុខភាពសត្វ និងសុខភាពសាធារណៈបសុព្យាបាល នាយកដ្ឋានផ្សព្វ ផ្សាយបច្ចេកទេស និងនីតិកម្ម និងវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ ព្រមទាំងការិយាល័យ មន្ទីរពិសោធន៍ និងស្ថានីយពិសោធន៍សរុបចំនួន៣២។ ជារួមនៅទូទាំងប្រទេសមន្ត្រីបម្រើការងារសុខភាពសត្វ និងផលិតកម្មសត្វមានចំនួនសរុប៨៨៦រូប ស្រី១៨៩នាក់ ដែលក្នុងនោះមន្ត្រីបម្រើការងារនៅថ្នាក់កណ្ដាល (អគ្គនាយកដ្ឋាន) មានចំនួន ២៨៨រូប ស្ត្រី៨៨រូប និងមន្ត្រីបម្រើការងារនៅទូទាំង២៥ រាជធានី-ខេត្ត មានសរុបចំនួន៥៩៨នាក់ ស្រី១០១នាក់ (ឧបសម្ព័ន្ធទី២០)។

### ៥.២. ការអភិវឌ្ឍន៍ធនធានមនុស្ស

ឆ្លើយតបទៅនឹងការកំណត់អាទិភាពនៃកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានយកចិត្តទុកដាក់ដល់ការបង្កើនសមត្ថភាពមន្ត្រីជាបន្តបន្ទាប់ ទាំងសមត្ថភាពរៀបចំ និងអនុវត្តផែនការ និងសមត្ថភាពបច្ចេកទេសសម្រាប់ផ្ដល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វឱ្យកាន់តែប្រសើរថែមទៀត ដោយបានគៀរគរជំនួយ និងការគាំទ្រនានាពីរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍សម្រាប់បង្កើនសមត្ថភាពមន្ត្រី និងអ្នកពាក់ព័ន្ធ ផ្ដោតលើអាទិភាពនៃការសិក្សាពីតម្រូវការបណ្ដុះបណ្ដាលទាំងចំណេះដឹង សមត្ថភាពគ្រប់គ្រង និង

សមត្ថភាពបច្ចេកទេស ដែលរួមមានជាអាទិ៍ការបណ្តុះបណ្តាលស្តីពីការងាររដ្ឋបាល និងបុគ្គលិក ការរៀបចំ និងគ្រប់គ្រងគម្រោង ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ ជំនាញគណនេយ្យ ការរៀបចំផែនការតាមទម្រង់P3 និងP4 ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ នីតិវិធីទូទាត់ថវិកា និងរៀបចំរបាយការណ៍តាមទម្រង់M1 និងM2 ប្រកបដោយគុណភាព ដោយបានបណ្តុះបណ្តាល និងសិក្ខាសាលា៦លើក ដែលមានអ្នកចូលរួមចំនួន៥៦៥នាក់។

## ៥.៣. ការងាររៀបចំផែនការ

ឆ្នាំ២០១៨នេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានចូលរួមរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រនានា ផ្តល់ធាតុចូលលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ កសាងផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០ សម្រាប់ត្រៀមរៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងទិសដៅការងារសម្រាប់អនុវត្តបន្ត ដោយធ្វើបច្ចុប្បន្នភាពលើផែនការ និងលើកទិសដៅសំខាន់ៗដូចខាងក្រោម៖

១. ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ (ផយថ ២០១៩-២០២១)។

២. ផែនការថវិកាតាមកម្មវិធីរបស់រាជរដ្ឋាភិបាលប្រចាំឆ្នាំ២០១៩។

៣.ផែនការជាតិលុបបំបាត់ជំងឺអុតក្តាម ដែលស្ថិតក្នុងក្របខ័ណ្ឌនៃយុទ្ធនាការតំបន់ ក្នុងការប្រយុទ្ធប្រឆាំងលុបបំបាត់ជំងឺអុតក្តាមនៃអង្គការសុខភាពសត្វពិភពលោក។

៤.ផែនការសកម្មភាពសម្រាប់លុបបំបាត់ជំងឺឆ្លងសត្វសំខាន់ៗចំនួន៤ គឺជំងឺអុតក្តាម សារទឹក បូសខ្យល់ និងជំងឺញូវកាស។

៥.អនុក្រុមការងារសុខភាពសត្វ និងផលិតកម្មសត្វ នៃក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ដែលមានសមាសភាពពីគ្រប់អ្នកពាក់ព័ន្ធ ព្រមទាំងបានដំណើរការក្រុមការងារនេះយ៉ាងសកម្ម។

៦.ផែនការសកម្មភាពបញ្ជ្រាបយេនឌ័រក្នុងវិស័យសុខភាពសត្វ និងផលិតកម្មសត្វ។

៧.ការរៀបចំ និងដាក់ឱ្យដំណើរការប្រព័ន្ធរបាយការណ៍ស្តង់ដារឯកភាពទូទាំងប្រទេសស្តីពីព័ត៌មានសុខភាពសត្វ និងផលិតកម្មសត្វ។

## ៥.៤. ការពង្រឹងការផ្តល់សេវាកម្មសុខភាពសត្វ និងផលិតកម្មសត្វ

សេវាកម្មសំខាន់ៗ ដែលអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បាននឹងកំពុងអនុវត្តរួមមានការត្រួតពិនិត្យ និងការផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យសត្វ និងផលិតផលសត្វ ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្មសត្វ និងផលិតផលសត្វ ការវិភាគគុណភាពចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម បសុឱសថ ការផ្តល់លិខិតអនុញ្ញាតធ្វើចរាចរសត្វ និងផលិតផលសត្វ ការអនុញ្ញាតនាំចេញ នាំចូល នាំឆ្លងកាត់សត្វរស់ និងផលិតផលសត្វ ការចេញលិខិតអនុញ្ញាតសម្រាប់បង្កើតសត្តឃាតដ្ឋាន លិខិតអនុញ្ញាតការចិញ្ចឹមសត្វ និងការបង្កាត់ពូជសត្វ ការចុះបញ្ជីចំណីសត្វ វត្ថុធាតុដើម និងសារធាតុបន្ថែម និងបសុឱសថ និងបង្ក្រាបល្មើសចលនាសត្វ និងផលិតផលសត្វ។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ស្ថិតនៅក្នុងកម្មវិធីទី២ ជំរុញផលិតកម្មសត្វ និងសុខភាពសត្វ មានអនុកម្មវិធីចំនួន៥ ក្នុងឆ្នាំ២០១៨ អនុវត្តបានចំនួន៩២%។

ក្នុងការបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាកម្មសាធារណៈ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងការិយាល័យផលិតកម្ម និងបសុព្យាបាលរាជធានី-ខេត្តទាំង២៥ នៅឆ្នាំ២០១៨ បានប្រមូលចំណូលសរុបចំនួន៩.៦៦៤.៥៣១.៩៣០រៀល ធៀបនឹងឆ្នាំ២០១៤ មានកំណើន៨១,៨៥% និងធៀបនឹងឆ្នាំ២០១៧ មានកំណើន២៧,២៩% ដែលក្នុងនោះថ្នាក់កណ្តាលកើនឡើង៣៨,៤៨% និងរាជធានី-ខេត្តកើនឡើង១១,៥៥% ធៀបនឹងឆ្នាំ២០១៧។

ក្រាហ្វិកប្រៀបធៀបលទ្ធផលប្រមូលចំណូលពីឆ្នាំ២០១៤-២០១៨




### ៥.៥. ការងារសហប្រតិបត្តិការ

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ បានសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍នានា អង្គការជាតិ និងអង្គការអន្តរជាតិ ដែលរួមមាន៖ OIE, FAO, ASEAN, EU, CHINA, ACIAR, IAEA, JICA, KOICA, AVSF, PIN, VSO, 2KR, UNIDO, DTRA។

#### ក. កិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍

អង្គការសុខភាពសត្វពិភពលោក (OIE) អង្គការស្បៀង និងកសិកម្មសហប្រជាជាតិ (FAO) និងប្រទេសអាស៊ាន ដៃគូអភិវឌ្ឍន៍ដូចជាសហភាពអឺរ៉ុប សាធារណៈរដ្ឋប្រជាមានិតចិន ACIAR, IAEA, JICA, KOICA បានត្រូវពង្រឹង និងពង្រីកស្របតាមអភិក្រមភាពជាម្ចាស់ និងបម្រើឱ្យកម្មវិធីអភិវឌ្ឍន៍នៃអនុវិស័យ។

#### ខ. កិច្ចសហការជាតិ និងអង្គការសង្គមស៊ីវិល

បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ សហការជាមួយអង្គការដៃគូមួយចំនួនដែលបាន នឹងកំពុងចូលរួមអភិវឌ្ឍន៍អនុវិស័យនេះ រួមមាន៖ អង្គការ AVSF, PIN, VSO, 2KR, UNIDO, CARE, HEIFER។

#### គ. កម្មវិធី និងគម្រោងសំខាន់ៗកំពុងអនុវត្ត

កម្មវិធី និងគម្រោងគាំទ្រការអភិវឌ្ឍន៍សុខភាពសត្វ និងផលិតកម្មសត្វ រួមមាន៖ គម្រោងថវិកាតាមកម្មវិធីរបស់រដ្ឋាភិបាល កម្មវិធីជំរុញកំណើនវិស័យកសិកម្មប្រកបដោយចីរភាព និងបរិយាប័ន្នៈអនុវិស័យជលផល និងអនុវិស័យផលិតកម្មសត្វ គម្រោងកែលម្អប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមហាអនុតំបន់មេគង្គ គម្រោងជីវៈ-សុវត្ថិភាពមូលដ្ឋានសម្រាប់គ្រប់គ្រងហានីភ័យជំងឺសត្វនៅកម្ពុជា គម្រោងគាំទ្រការចិញ្ចឹមសត្វដោយនិរន្តរភាព និងកម្មវិធីឡជីវឧស្ម័នរដ្ឋាភិបាលចិន។

## V. កាលានុវត្តភាព និងបញ្ហាប្រឈម

កម្ពុជាមានសក្តានុពលអភិវឌ្ឍផលិតកម្មសត្វផ្អែកលើទីតាំងភូមិសាស្ត្រជាយុទ្ធសាស្ត្រនៅក្នុងអាស៊ាន និងអនុ-តំបន់ទន្លេមេគង្គ មានផ្ទៃដីកសិកម្មធំទូលាយមិនទាន់ប្រើប្រាស់អស់សក្តានុពល ដែលផ្តល់លក្ខខណ្ឌសមស្របក្នុងការចិញ្ចឹមសត្វ និងដាំដំណាំចំណីសត្វ។ ការកើនឡើងចំនួនប្រជាជន និងភ្ញៀវទេសចរណ៍ជារៀងរាល់ឆ្នាំ បានធ្វើឱ្យមានកំណើនតម្រូវការសាច់ក្នុងស្រុកទាមទារឱ្យមានការបង្កើនផលិតកម្មសត្វ ការស្រាវជ្រាវសុខភាពសត្វនិងផលិតកម្ម

សត្វ ការកែច្នៃផលិតផលសត្វ និងចំណីសត្វនិងដំណាំចំណីសត្វ។ ប៉ុន្តែជាមួយនឹងកាលានុវត្តភាពខាងលើទាំងនេះ ការអភិវឌ្ឍន៍អនុវិស័យសុខភាពសត្វ និងផលិតកម្មសត្វ ជួបនូវបញ្ហាប្រឈមមួយចំនួន ដោយសារកត្តាផ្សេងទៀតមានជាអាទិ៍ ១).ភាពយឺតយ៉ាវនៃការប្តូរឥរិយាបទពីផលិតកម្មសត្វតាមបែបប្រពៃណី ទៅជាផលិតកម្មសត្វតាមបែបពាណិជ្ជកម្ម ២).បរិយាកាសសម្រាប់ការរីកលូតលាស់នៃពាណិជ្ជកម្មសត្វនៅមានកម្រិត ជាពិសេសពាក់ព័ន្ធនឹងធាតុចូលសំខាន់ៗ ដូចជា តម្លៃអគ្គិសនីខ្ពស់ ខ្វះកម្លាំងពលកម្ម សត្វ និងផលិតផលសត្វមិនទាន់ស្របតាមស្តង់ដារទីផ្សារតម្រូវ បទដ្ឋានគតិយុត្តមិនទាន់គ្រប់ជ្រុងជ្រោយដើម្បីសម្រួលពាណិជ្ជកម្មសត្វ ៣). ខ្វះសម្ភារឧបករណ៍បម្រើការស្រាវជ្រាវនៅមន្ទីរពិសោធន៍ ៤). ប្រព័ន្ធគ្រប់គ្រងអនាម័យ និងភូតគាមអនាម័យនៅមានកម្រិត ៥). ធនធានមនុស្សនៅមានកម្រិត។

## VI. ទិសដៅអនុវត្តឆ្នាំ២០១៩-២០២០

### ក. សូចនាករទិសដៅ

- បង្កើនផលិតផលសាច់ឱ្យកើនពី៣១៦ពាន់តោននៅឆ្នាំ២០១៩
- បង្កើនអត្រានៃការចិញ្ចឹមជាលក្ខណៈពាណិជ្ជកម្មឱ្យកើន២០%នៅឆ្នាំ២០១៩
- ពង្រីកការប្រើប្រាស់ពូជគោកូនកាត់ ទាំងការចិញ្ចឹមជាលក្ខណៈគ្រួសារ និងពាណិជ្ជកម្ម២០%។

### ខ. វិធានការអនុវត្តដើម្បីសម្រេចទិសដៅកំណត់

#### ១.បង្កើនផលិតកម្មសត្វ

